# មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

# វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

## សេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ែម តំបន់ទី ៦

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

## ថ្ងៃអង្គារ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦

## ខេត្តកំពង់ចាម

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក **ឡារី ស្ត្រេនួ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

០២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ូម (COPCELPROM) ដោយលោក **ឱក សេរី សោភ័ក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

០៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក **មាង ម៉េងហ៊ួន** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម

០៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តកំពង់ចាម

០៥. សេចក្តីផ្សេងៗ

### ០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ឡារី ស្ត្រេនួ (Larry Strange) នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

ក្នុងនាមវិទ្យាស្ថាន CDRI លោកមានសេចក្តីរីករាយណាស់ដែលបានចូលរួមនៅក្នុងខប់សែលប្រ៉ូមថ្នាក់ខេត្ត នៅខេត្តកំពង់ចាមនេះ លោកសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះសមាជិកអង្គប្រជុំដែលបានចូលរួមក្នុងអង្គប្រជុំនេះ ។ ដោយនៅក្នុងសប្តាហ៍នេះវិទ្យាស្ថាន CDRI មានការមមាញឹកនៅក្នុងការរៀបចំខប់សែលនៅថ្នាក់ខេត្ត ដែលថ្ងៃនេះបានធ្វើនៅខេត្តកំពង់ចាម ហើយម្សិលមិញធ្វើនៅខេត្តក្រចេះ ជាបន្តនឹងទៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ។ នៅក្នុងកិច្ចប្រជុំខប់សែលប្រ៉ូមនីមួយៗវិទ្យាស្ថាន CDRI មានកិត្តយសមោទនៈភាព និងសេចក្តីរីករាយដែលបានឃើញការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធនានាជុំវិញការងារបោះឆ្នោត ហើយបានលើកបញ្ហានានាយកមកពិភាក្សាយ៉ាងផុលផុស និងសកម្ម ជាពិសេសប្រកបដោយការគោរព និងយោគយល់គ្នាចំពោះការលើកឡើងនូវមតិទាំងឡាយ ។

ឆ្លៀតក្នុងឱកាសនេះលោកសូមថ្លែងអំណរគុណចំពោះក្រសួងមហាផ្ទៃ ជាពិសេសឯកឧត្តម ហ៊ុន ណេង អភិបាលខេត្តកំពង់ចាម ដែលបានអនុញ្ញាតឱ្យខប់សែលបានដំណើរការ និងធ្វើការរៀបចំកិច្ចប្រជុំនៅពេលនេះ ។ ទន្ទឹមនិងនេះដែរសូមថ្លែងអំណរគុណដល់លោកប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ។ លោកក៏សូមថ្លែងអំណរគុណដល់ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដែលបានគាំទ្រលើផ្នែកហិរញ្ញវត្ថុទាំងមូលលើការរៀបចំខប់សែលនេះ ជាពិសេសសូមស្វាគមន៍ចំពោះអ្នកស្រី Margie Cook ជាតំណាងពិសេសរបស់ UNDP និងជាអ្នកជំនាញការផ្តល់ផ្នែកការងារបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងសហការីរបស់អ្នកស្រីផងដែរ ។ លោកក៏សូមថ្លែងអំណរគុណដល់អង្គប្រជុំទាំងអស់ដែលបានចូលរួមក្នុងអង្គប្រជុំនេះ ជាពិសេសតំណាងក្រសួងមហាផ្ទៃ តំណាងស្នងការ តំណាងយោធាភូមិភាគ អាជ្ញាធរខេត្តស្រុក អភិបាលស្រុក អភិបាលរងស្រុក ក្រុមប្រឹក្សាឃុំសង្កាត់ អង្គការសង្គមស៊ីវិល និងគណបក្សទាំងអស់ ។ លោកនឹងបង្ហាញជូនអង្គប្រជុំជ្រាបថា ហេតុអ្វីបានជាខប់សែលមានសារៈសំខាន់សំរាប់វិទ្យាស្ថាន CDRI ។

វិទ្យាស្ថាន CDRI គឺជាវិទ្យាស្ថានមួយធ្វើការសិក្សាស្រាវជ្រាវដោយឯករាជ្យអំពីគោលនយោបាយដើម្បីអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាប្រកបដោយចិរភាព ដែលការងារចំបងសំខាន់ គឺជាចំណុចគន្លឹះៗនៃការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ។ អ្វីដែលជា

ជំហ៊ានដែលទទួលបាននូវការអភិវឌ្ឍន៍ប្រកបដោយចិរភាព គឺត្រូវធានាឱ្យបាននូវសន្តិភាព និងសន្តិសុខឱ្យបានគ្រប់គ្រាន់ ។ វិទ្យាស្ថាន CDRI យល់ថាដំណើរការបោះឆ្នោតគឺជាក្បាលម៉ាស៊ីនមួយដែលឆ្ពោះទៅរកការកសាងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ តាមរយៈការសិក្សាស្រាវជ្រាវទៅលើការបោះឆ្នោត បានបង្ហាញឱ្យឃើញថា ចាប់តាំងពីឆ្នាំ ១៩៩៣ ជាបណ្តើរការគ្រប់គ្រង ការអនុវត្តន៍នូវការរៀបចំការបោះឆ្នោត មានភាពប្រសើរជាបណ្តើរៗ ប៉ុន្តែនៅមានបញ្ហាប្រឈមជាច្រើនដែលយើងត្រូវការធ្វើឱ្យកាន់តែប្រសើរឡើងជាងនេះទៀត ។ ដោយមើលឃើញនូវបញ្ហាប្រឈមទាំងអស់នេះហើយបានជាវិទ្យាស្ថាន CDRI មានគោលបំណង និងមានឆន្ទះមួយធ្វើយ៉ាងណារៀបចំជាយន្តការមួយ ដើម្បីជំរុញឱ្យមានវប្បធម៌នៃការជជែកពិភាក្សាគ្នា ត្រង់ទៅត្រង់មក ចំពោះមុខគ្នា ដើម្បីកសាងនូវលទ្ធិប្រជាធិបតេយ្យមួយឱ្យបានពិតប្រាកដ ។

លោកក៏បានជំរុញឱ្យអង្គប្រជុំទាំងមូលចូលរួមនៅការលើកឡើងជាបញ្ហានានា ដើម្បីពិភាក្សានៅចំពោះមុខគ្នា ប្រកបដោយការយោគយល់គ្នាជាទីបំផុត ។ ជោគជ័យទាំងឡាយរបស់កិច្ចប្រជុំខប់សែលប្រ៉ុមនីមួយៗអាស្រ័យលើការចូលរួមដ៏ផុសផុលពីលោកស្រីអស់លោក នៅក្នុងការលើកឡើងនូវមតិយោបល់ ឬបញ្ហានានាដែលកើតមាននៅក្នុងមូលដ្ឋាន ជុំវិញការងារបោះឆ្នោត ។ លោកក៏បានគោរពជូនពរឱ្យការប្រជុំនេះប្រកបដោយផ្លែផ្កា និងទទួលបានជោគជ័យ លើបញ្ហាដែលកើតមាននៅក្នុងមូលដ្ឋាន ។

**អ្នកស្រី Margie Cook** តំណាងអង្គការ UNDP បានមានប្រសាសន៍ថា នេះគឺជាលើកទី ១ដែលអ្នកស្រីបានមកទស្សនៈកិច្ចតាមខេត្ត ហើយជាកិត្តយស និងមានសេចក្តីរីករាយជាទីបំផុតដែលបានចូលរួមនៅក្នុងកិច្ចប្រជុំខប់សែលប្រ៉ុមនៅខេត្តកំពង់ចាម ។ អ្នកស្រីមកពីប្រទេសអូស្ត្រាលី ហើយជាង ៦ឆ្នាំកន្លងមកអ្នកស្រីធ្លាប់បានធ្វើការជាមួយ UNDP នៅអាហ្វ្រិចខាងត្បូង ដែលធ្វើការពាក់ព័ន្ធទៅនិងរឿងបោះឆ្នោត ដូចជាប្រទេស TANZANIA NIGERIA និងប្រទេស KENYA ។ អ្នកស្រីបានជំរាបជូនអង្គប្រជុំជាសង្ខេបពីកម្មវិធីរបស់ UNDP ដែលនៅក្នុងខ្មែរ UNDP មានកម្មវិធីគាំទ្រជាច្រើនទៅលើបញ្ហានានា នៅក្នុងការអភិវឌ្ឍន៍ ឬបញ្ហាផ្សេងៗ ជាពិសេសមានកម្មវិធីមួយដែលគាំទ្រដល់ផ្នែកការបោះឆ្នោត ដែលផ្តោតសំខាន់ទៅលើ គជប នៅប្រទេសកម្ពុជា ដែលធ្វើការសំខាន់ផ្តោតទៅលើរឿងកំណែទម្រង់ផ្លូវច្បាប់ គាំទ្រលើការបណ្តុះបណ្តាល ការផ្សព្វផ្សាយផ្សេងៗ ។ សហការីរបស់អ្នកស្រីគឺលោក Denis Truesdell ជាជំនាញផ្ទាល់ ដែលធ្វើការពាក់ព័ន្ធយ៉ាងជិតស្និត និងនៅជាមួយ គជប ។

នៅក្នុងផ្នែកមួយទៀត UNDP មានកម្មវិធីគាំទ្រលើផ្នែកសមធម៌សារព័ត៌មាន ដែលយើងហៅថាផ្នែកសារព័ត៌មានធ្វើយ៉ាងណា ដើម្បីឱ្យមានការសមភាពស្មើភាពនៅក្នុងការចូលរួម តាមរយៈសារព័ត៌មាន ។ ក្នុងការអនុវត្តន៍កម្មវិធីដែលមានរយៈពេលវែងជាពិសេសលើការអប់រំចំពោះប្រជាពលរដ្ឋទាក់ទងនិងការងារបោះឆ្នោត UNDP មានគំរោង និងកំពុងតែគាំទ្រដល់វិទ្យាស្ថាន CDRI ជាពិសេសតាមរយៈកម្មវិធីខប់សែលនេះ ។ ការដោះស្រាយទំនាស់ និងវិវាទផ្សេងៗនៅក្នុងការបោះឆ្នោត គឺជាចំណុចមួយសំខាន់នៅក្នុងដំណើរការនៃការបោះឆ្នោតប្រព្រឹត្តទៅបានល្អ ដែលនេះជាចំណុចមួយដែលខាងអ្នកស្រីកំពុងតែផ្តោតការយកចិត្តទុកដាក់ ។ នៅក្នុងកម្មវិធីផ្សេងៗដែលអ្នកស្រីបានចុះទៅធ្វើការជាមួយ មានទម្រង់ប្រហាក់ប្រហែលគ្នានិងកម្មវិធីនេះ ប៉ុន្តែគ្រាន់តែមិនបានបញ្ចូលនៅគ្រប់ភាគីពាក់ព័ន្ធនៅក្នុងការពិភាក្សា ។ ដូចដែលលោក Larry Strange បានមានប្រសាសន៍អ្នកស្រីយល់ស្របថា ជារឿងមួយល្អណាស់ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការពិភាក្សានៅតុមូលនេះ ដើម្បីលើកឡើងនៅបញ្ហានានាជុំវិញការងារបោះឆ្នោត ដែលមានតាំងពីខាង គខប ខាងអាជ្ញាធរ និងអង្គការសង្គមស៊ីវិលនានា ជាពិសេសតំណាងគណបក្សនយោបាយទាំងអស់ ។

អ្នកស្រីបានជូនពរឱ្យការប្រជុំនេះនឹងប្រកបដោយផ្លែផ្កា និងទទួលបានជោគជ័យជាទីបំផុត ។

## ០២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ូម (COPCELPROM) ដោយលោក ឱក សេរី សោភ័ក្ត្រ ទីប្រឹក្សា និង ជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

លោកផ្ទាល់បានចេញពីប្រទេសកម្ពុជាមុនពេលខ្មែរក្រហមចូលមក ហើយបានទៅរៀនវិជ្ជាពេទ្យនៅប្រទេសបារាំង ។ នៅឆ្នាំ ១៩៨១ បានចូលរួមនៅក្នុងអង្គការសិលការ នៅតាមជាយដែនខ្មែរថៃ ។ នៅក្នុងពេល ១១ឆ្នាំនោះលោកបានឃើញសោកនាដកម្ម ការដែលខ្មែរគ្នាឯងមានសង្គ្រាមប្រល័យពូជសាសន៍ ដែលធ្វើឱ្យប្រជាជនវេទនា ខ្លោចផ្សារ ។ ក្នុងពេលនោះលោកស្អប់នៅសង្គ្រាម អាវុធ អំពើហិង្សា ហើយគិតថានៅពេលបានចូលមកស្រុកវិញ លោកធ្វើយ៉ាងណាដើម្បីចូលរួមចំណែកដើម្បីកុំឱ្យមានរឿងនេះកើតឡើងទៀតបាន ។ បន្ទាប់ពីបោះឆ្នោតអ៊ុនតាក់នៅឆ្នាំ ១៩៩៣ មក លោកបានមកធ្វើជានាយកខុទ្ទកាល័យ និងជាទីប្រឹក្សារបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ដែលលោកផ្ទាល់ជាអ្នករៀបចំការងាររៀបចំការបោះឆ្នោតជាមួយអង្គការសហប្រជាជាតិ និងជាមួយប្រទេសធំៗមួយចំនួន ។ នៅឆ្នាំ ១៩៩៣ អ៊ុនតាក់ជាអ្នករៀបចំការបោះឆ្នោតឱ្យប្រទេសកម្ពុជា ក្រោយមកនៅឆ្នាំ ១៩៩៨ ខ្មែររៀបចំដោយខ្លួនឯងដោយគ្មានបទពិសោធន៍ និងធ្លាប់ពឹងគេទាំងអស់ ។ កាលដែលពឹងលើគេទាំងអស់នេះហើយ ដែលឆ្នាំ ១៩៩៧ បានឆ្លងកាត់ការឈ្លោះគ្នាម្តងទៀត រហូតដល់ឆ្នាំ ១៩៩៨ ពេលដែលបោះឆ្នោតហើយយើងក៏មានអំពើហិង្សារហូតដល់មានរូបភាពឃោរឃៅ រូបភាពហិង្សាលើលើទូរទស្សន៍អន្តរជាតិបង្ហាញនៅលើសកលលោក ។

លោកបានគិត ហើយសួរខ្លួនឯងថា ហេតុអ្វីបានជាប្រទេសកម្ពុជាចេះតែស្រឡាញ់អំពើហិង្សា ម្តងហើយម្តងទៀត មិនចេះរាងចាល មិនចេះរៀនសូត្រពីសោកនាដកម្មរបស់ខ្លួនឯង ដើម្បីធ្វើការឱ្យបានប្រសើរឡើង ។ លោកឃើញថាមូលហេតុធំចំបងជាងគេគឺនៅក្នុងសង្គមរបស់យើងការដែលមានបញ្ហាអ្វីកើតឡើង យើងមិនចេះនិយាយត្រង់ទៅត្រង់មកទេ យើងច្រើនតែញញឹមដាក់គ្នា ប៉ុន្តែនៅពីក្រោយយើងនិយាយអាក្រក់ យើងវាយប្រហារគ្នា ដូច្នេះត្រូវតែមានយន្តការណាមួយដើម្បីដោះស្រាយ ហើយប្តូរទំលាប់ ប្តូរការគិតពិចារណានេះឡើង ។ នៅឆ្នាំ ១៩៩៩ លោកក៏បានចូលទៅធ្វើការនៅវិទ្យាស្ថាន CDRI រហូតដល់ឆ្នាំ ២០០៣ ក្រោយពីមានបទពិសោធន៍ជាមួយរាជរដ្ឋាភិបាល ។ នៅឆ្នាំ ១៩៩៩ លោកបានចូលរួមធ្វើការស្រាវជ្រាវថាហេតុអ្វីបានជាការបោះឆ្នោតឆ្នាំ ១៩៩៨ មានអំពើហិង្សាខ្លាំងពេក លោកបានរកឃើញនូវមូលហេតុ៧-៨ធំៗជាលក្ខណៈយុទ្ធសាស្ត្រ នៅពេលនោះលោកបានដកខ្លួនទៅសមាធិជាមួយព្រះសង្ឃជាច្រើនវត្ត និងបានដកខ្លួនពិចារណាហើយក៏នឹកឃើញយន្តការខប់សែលនេះឡើង ។ យន្តការខប់សែលនេះយើងចង់បំរើតែការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ ២០០២ ទេ ដែលមានការគាំទ្រយ៉ាងខ្លាំងពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ឯកឧត្តម អ៊ឹម សួស្តី គណបក្សនយោបាយទាំងអស់ អង្គការសង្គមស៊ីវិល ដូចជាខុមហ្វ្រែល និកហ្វិច ដែលយន្តការនេះបានសាងឡើងដោយដៃខ្មែរសុទ្ធសាធ ។ យន្តការនេះយើងបានធ្វើតែនៅថ្នាក់ជាតិទេ មានជំនុំ ៥០ដងរយៈពេល៤ឆ្នាំ មួយខែម្តងៗមិនដែលខានទេ ដោយមានការទទួលជោគជ័យខ្លាំង អ្នកទាំងអស់ក៏ជំរុញឱ្យមានយន្តការខប់សែលបំរើការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំ ២០០៣ ថែមទៀត ។ ខប់សែលដំណាក់កាលទី១បានចប់នៅឆ្នាំ ២០០៣ ។

ក្រោយមកអង្គការ UNDP ជាពិសេសលោក Douglas gadner បានមើលរបាយការណ៍ខប់សែលនេះ លោកគិតថាយន្តការនេះគឺបង្កើតឡើងដោយដៃខ្មែរដោយខ្លួនឯង ហើយប្រទេសដែលទើបតែចេញពីសង្គ្រាមឯទៀត ដែលត្រូវការផ្សះផ្សារ បង្រួបបង្រួមជាតិរកមិនឃើញទេ ដូច្នេះគួរតែបន្តទៀតដើម្បីបំរើការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៧ និងថ្នាក់ជាតិឆ្នាំ ២០០៨ ហើយ UNDP អាចរៀនសូត្រពីអ្វីដែលប្រទេសកម្ពុជាបានបង្កើតឡើងដោយដៃខ្លួនឯង ដើម្បីយកទៅអនុវត្តនៅប្រទេសផ្សេងៗទៀត ។

បន្ទាប់មកលោកបានដកខ្លួនចេញម្តងទៀត បានទៅជួបនិងព្រះសង្ឃ អាចារ្យវត្ត ដូនជី និស្សិត ហើយលោក Larry និងលោកផ្ទាល់ក៏បានជួបជាមួយអភិបាលខេត្ត និងតួអង្គធំៗ ហើយក៏បានគិតថាទំនាស់កើតឡើងច្រើនតែមានប្រភពមកពីមូលដ្ឋាន ។ ដូច្នេះបើសិនជាយើងនៅតែធ្វើនៅថ្នាក់ជាតិ ប្រហែលជាមិនសូវមានប្រសិទ្ធិភាពប៉ុន្មានទេ អញ្ចឹងហើយបានជាយើងបង្កើតខប់សែលប្រ៊មនេះឡើង ។ អញ្ចឹងហើយបានជានៅក្នុងអង្គប្រជុំនេះ យើងឃើញមានវត្តមានក្រុមប្រឹក្សាឃុំសង្កាត់ច្រើន យ៉ាងតិច ៤០នាក់ ព្រោះគាត់នេះហើយដែលស្គាល់នូវមូលហេតុ ឬគល់នៃទំនាស់ដែលកើតមានឡើងនៅថ្នាក់មូលដ្ឋាននៅក្នុងយន្តការនៃការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ និងការបោះឆ្នោតនៅថ្នាក់ជាតិឆ្នាំ ២០០៨ ។ លោកគិតថាបើសិនជាយើងដោះស្រាយ និងបង្ការទំនាស់បាននៅថ្នាក់មូលដ្ឋាន បញ្ហានឹងមិនឡើងទៅថ្នាក់ជាតិ ហើយបញ្ហាបច្ចេកទេសទាំងអប្បាលមានយើងអាចនិយាយស្តាប់គ្នាបាន មិនក្លាយទៅជាបញ្ហានយោបាយនៅថ្នាក់ជាតិទេ ។ ទាំងអស់នេះគឺជាហេតុផលដែលនាំឱ្យមានការបង្កើតឡើងនៅខប់សែលដំណាក់កាលទី២ ហើយមានផ្នែកមួយនៃខប់សែលដំណាក់កាលទី២នេះ គឺខប់សែលប្រ៊ម ។

ដូចដែលអង្គប្រជុំបានជ្រាបហើយ ដំណាក់កាលនៃការបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ការចុះឈ្មោះបេក្ខជន គណបក្សនយោបាយ យុទ្ធនាការឃោសនា ថ្ងៃបោះឆ្នោត ថ្ងៃរាប់សន្លឹកឆ្នោត ការប្រកាសលទ្ធផល និងការដោះស្រាយវិវាទ គ្រប់ដំណាក់កាលទាំងអស់សុទ្ធតែមានទំនាស់ ។ យន្តការខប់សែលយល់ថាមានទំនាស់ ៣ដែលមានលក្ខណៈជាយុទ្ធសាស្រ្ត បើសិនជាយើងដោះស្រាយបានទៅថ្ងៃមុខយើងអាចគ្រប់គ្រង យើងអាចត្រួតត្រាយន្តការនៃការបោះឆ្នោតនៅប្រទេសកម្ពុជា បានដោយស្ថេរភាព និងសន្តិសុខ ។ ខប់សែលមានគោលបំណង ៣ធំៗ

**ទី១** ការចុះឈ្មោះបោះឆ្នោត ដែលមិនអាចចេះតែធ្វើហើយមានបញ្ហា ឱ្យតែចុះឈ្មោះមានបញ្ហាៗ យើងមិនអាចធ្វើអញ្ចឹងបានទេ ប៉ុន្តែប្រទេសយើងទើបតែចេញពីសង្រ្គាមពិតប្រាកដនៅឆ្នាំ ១៩៩៨ អញ្ចឹងបទពិសោធនបានប្រហែល ៨ឆ្នាំដែលយើងបានធ្វើនៅក្នុងសន្តិភាពពិតប្រាកដ នេះយើងកំពុងតែរៀនសូត្រ ។ ប្រជាពលរដ្ឋមិនសូវវិវរវល់និងការចុះអត្រានុកូលដ្ឋានទេ ហើយជួនកាលមានការដូរឈ្មោះច្រើន ហើយលោកប៉ូលីស និងស្មៀនឃុំសង្កាត់ក៏មានការសរសេរឈ្មោះខុស នាំឱ្យមានការវិលវល់ជុំវិញខុសទាំងអស់គ្នា ។ នេះជាការធម្មតានៅពេលដែលយើងក៏សាងប្រព័ន្ធមួយថ្មី ដែលយើងទើបតែចេញពីសង្រ្គាម ។ ដូច្នេះបានជាយើងយកចិត្តទុកដាក់ថាការចុះឈ្មោះបោះឆ្នោត យើងធ្វើការតស៊ូមតិដើម្បីឱ្យមានការខុសឆ្គងបន្តិបន្តួចយើងអនុគ្រោះ ហើយធ្វើយ៉ាងម៉េចឱ្យប្រជាពលរដ្ឋបោះឆ្នោតបាន ។ ដូច្នេះយើងគាំទ្រជួយ គជប ច្រើនណាស់នៅក្នុងរឿងអស់នេះ ។ ការដែលបោះឆ្នោតត្រៀម ៩ខែ ពីខែមករា ដល់ខែកញ្ញា គឺជារបៀបថ្មីដែលយើងបង្កើតឡើង ដើម្បីឱ្យប្រជាពលរដ្ឋអាចត្រៀមលក្ខណៈជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ៩ខែ ហើយចុះឈ្មោះមែនទែនក្នុងរយៈពេល ២០ថ្ងៃ តែឆ្នាំនេះ គជប បន្ថែមដល់ទៅ ២៤ថ្ងៃ ។

**ទី២** អត្តសញ្ញាណប័ណ្ណជាតិ ខប់សែលចង់ធ្វើយ៉ាងណា ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរគ្រប់ៗគ្នាដែលមានអាយុគ្រប់ ១៨ឆ្នាំ ទទួលបានអត្តសញ្ញាណប័ណ្ណជាតិ ។ ខប់សែលបានធ្វើការជាមួយក្រសួងមហាផ្ទៃ ៣ខែ នៅឆ្នាំ ២០០៥ នៅពេលដែលឯកឧត្តមឧបនាយករដ្ឋមន្រ្តី ស ខេង លោកឃើញបែបនេះទើបលោកយល់ថាបញ្ហាអត្តសញ្ញាណប័ណ្ណជាតិ គឺជាការសំខាន់ណាស់ ។ ឯកឧត្តមបានចាប់ផ្តើមនៅខែ មករា ឆ្នាំ ២០០៦ ដោយដាក់បទបញ្ជាចុះមកគ្រប់ខេត្តទាំងអស់ឱ្យធ្វើយុទ្ធនាការគំហុកឆ្នាំ ២០០៦ ឱ្យចេញអត្តសញ្ញាណប័ណ្ណជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំ ដែលនៅមានចំនួន ១លាន៩សែននាក់ ឱ្យទទួលបានអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នា រហូតដល់ខែធ្នូ ឆ្នាំ២០០៦ ។ តាមដែលខប់សែលក្តាប់បានខេត្តទាំងអស់ទទួលបានលទ្ធផលប្រហែល ៨៥-៩០% មកទល់និងពេលនេះ ។

**ទី៣** សុវត្ថិភាព ខប់សែលចង់ធ្វើយ៉ាងណាឱ្យមានការចូលរួម ដូចដែលយើងបានអង្គុយនៅក្នុងអង្គប្រជុំនេះ ពេលដែលបោះឆ្នោតម្តង១ត្រូវតែជាការបោះឆ្នោតដែលអាចទទួលយកបាន ដែលគ្មានអំពើហិង្សា ហើយសកលលោកមើលមកឃើញថាខ្មែរចេះបង្ការទំនាស់ដោយខ្លួនឯង ចេះរៀបចំការបោះឆ្នោតមួយដូចជាប្រទេសរុងរឿង ដូចដែលយើងមានអង្គវត្តសំរាប់បង្ហាញគេ ។ យើងលាងអ្វីដែលជារូបភាពកខ្វក់កាលពីអតីតកាល ការសំលាប់រង្គាល អំពើហិង្សា ដោយយកវប្បធម៌នៃការជជែកពិភាក្សាគ្នាមកជំនួសវិញ ។

លោកផ្ទាល់គិតថានៅពេលចប់ឆ្នាំ ២០០៨ មិនត្រូវឱ្យមានយន្តការខប់សែលតទៅទៀតទេ យើងត្រូវតែចូលជាទំលាប់មួយនៅក្នុងការជជែកពិភាក្សាគ្នា ។

## ០៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក មាន ម៉េងហ៊ួន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម

លោកបានមានប្រសាសន៍ថាវត្តមានរបស់អង្គប្រជុំទាំងអស់ គឺជាជំនួយដ៏ប្រសើរថ្លៃថ្លា ដើម្បីជួយការងារបោះឆ្នោតទៅអនាគត ជាពិសេសថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៧ ខាងមុខនេះ ជាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំដែលប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ ដែលជាឱកាសមួយសំរាប់ឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលកាន់តែរីកចំរើនទៅមុខជាលំដាប់ ។ ចំពោះស្ថានភាពទូទៅជុំវិញដំណើរការរៀបចំការបោះឆ្នោត ខេត្តកំពង់ចាមក៏ដូចជាខេត្តក្រុងក្នុងប្រទេសកម្ពុជាដែលបានរៀបចំការបោះឆ្នោតជាសកលដោយខ្លួនឯងចំនួន ៣លើក ។ លើកទី១ នៅឆ្នាំ ១៩៩៨ លើកទី២ នៅឆ្នាំ ២០០២-២០០៣ និងការបោះឆ្នោតអសកលចំនួនមួយលើកនៅថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០៦ ។ ចន្លោះពីការបោះឆ្នោតនីមួយ១ គជប បានខិតខំកែលំអច្បាប់ និងនីតិវិធីឱ្យកាន់តែមានលក្ខណៈងាយស្រួល និងមានតម្លាភាព ។ ស្របតាមអនុសាសន៍ពីគណបក្សនយោបាយ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលមានតួនាទីឃ្លាំមើលការបោះឆ្នោតនៅកម្ពុជា អំពើហិង្សាក៏បានកាត់បន្ថយជាលំដាប់ ឯការបោះឆ្នោតក៏បានប្រព្រឹត្តទៅដោយមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។

ការបោះឆ្នោតអាចទទួលបានលទ្ធផលល្អដោយសារកត្តាធំ១មួយចំនួន

**ទី១** ពង្រឹងសមត្ថភាពដល់មន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់ ដែលជាអាជ្ញាធរបោះឆ្នោតទទួលបន្ទុកគ្រប់ផ្នែក និងឱ្យយល់ច្បាស់ពីតួនាទី និងភារកិច្ច និងមានសមត្ថភាពអាចបំពេញការងាររបស់ខ្លួនឱ្យបានសំរេច តាមផែនការ ។

**ទី២** ពិនិត្យនិងចាត់វិធានការទប់ស្កាត់រាល់ឧបាយកល និងការធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការបោះឆ្នោត តាមគ្រប់រូបភាពដោយបានសហការ និងទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ជាមួយការិយាល័យសន្តិសុខគ្រប់ឋានានុក្រម សំដៅធានាឱ្យមានសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពជុំវិញកិច្ចដំណើរការរៀបចំការបោះឆ្នោត ។

**ទី៣** ស៊ើបអង្កេត និងស្រាវជ្រាវ ដើម្បីសំរបសំរួល ឬដោះស្រាយបណ្តឹងពីគ្រប់មជ្ឈដ្ឋាន ដោយយុត្តិធម៌និងតម្លាភាព ដើម្បីឱ្យមានការជឿទុកចិត្តធ្វើឱ្យបរិយាកាសនយោបាយអព្យាក្រឹត្យ ប្រជាធិបតេយ្យ សេរី និងតម្លាភាព ។

ការបោះឆ្នោតដែលប្រព្រឹត្តទៅបាន គឺអាស្រ័យមានបញ្ជីឈ្មោះអ្នកបោះឆ្នោតត្រឹមត្រូវ ការធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកបោះឆ្នោត ដែលត្រូវប្រព្រឹត្តជារៀងរាល់ឆ្នាំ នៅថ្ងៃ ០១ ដល់ថ្ងៃ២០ ខែតុលា ។ កន្លងមកការផ្តល់ប្រតិភូកម្មអំណាចជូនដល់ឃុំ និងស្មៀនជាមន្ត្រីអ្នកចុះឈ្មោះបោះឆ្នោត ចាប់ពីឆ្នាំ ២០០៤ ការធ្វើបញ្ជីអ្នកបោះឆ្នោតកាន់តែប្រសើរ កាន់តែច្បាស់លាស់ និងពិតប្រាកដ ។

នៅឆ្នាំ ២០០៦ នេះដើម្បីសំរួលដល់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គជប បានផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតតាមរយៈលេខាធិការដ្ឋាន ដល់ក្រុមប្រឹក្សាឃុំ ដើម្បីជូនដំណឹងអំពីឈ្មោះ និងទិន្នន័យក្នុងបញ្ជីអ្នកបោះឆ្នោត ។ កន្លងមកនេះលេខាធិការដ្ឋានក៏បានអនុវត្តនៅភារកិច្ចរបស់ខ្លួនដូចតទៅ :

ដំណាក់កាលទី១ ការផ្តល់ប័ណ្ណព័ត៌មានតាមរយៈក្រុមប្រឹក្សាឃុំ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៦ ហើយបានទទួលលទ្ធផល ៨៤%លើ៤៤ នៃប័ណ្ណបានចែកជូនដល់ប្រជាពលរដ្ឋ ។ កែតំរូវឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតបាន ៦០% ដែលមានឈ្មោះ និងទិន្នន័យខុសពីឯកសារបញ្ជាក់អត្តសញ្ញាណ ។

ដំណាក់កាលទី២ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០០៦ ទទួលបានលទ្ធផលដូចតទៅ:

ការចុះឈ្មោះអ្នកបោះឆ្នោតថ្មីបានចំនួន ១៦៥ ៦៥៩ នាក់ ។ ការលុបឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០០៦ បានចំនួន ១៩ ៨៨៨ នាក់ ។ អ្នកបោះឆ្នោតឆ្នាំ ២០០៦ សរុបមានចំនួន ១ ០៧៣ ៥២៤ នាក់ បើប្រៀបធៀបចំនួនអ្នកបោះឆ្នោតនៅឆ្នាំ ២០០៥ មានតែ ៩២៧ ៨៥៣ នាក់ ។ ចំនួនការិយាល័យបោះឆ្នោតសំរាប់ឆ្នាំ ២០០៦ មានចំនួន ២ ០២៦ ការិយាល័យបោះឆ្នោត ។

លោកក៏បានជំរាបជូនអង្គប្រជុំផងដែរថា ចាប់ពីថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០៦ លេខាធិការដ្ឋានកបានត្រូវប្តូរឈ្មោះជាគណៈកម្មាការរៀបចំការបោះឆ្នោតខេត្ត ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៧ ខាងមុខនេះ ។ ក្នុងកិច្ចដំណើរការបោះឆ្នោត គខប នឹងត្រូវទទួលបន្ទុក និងអនុវត្តការងារដែល គជប ប្រគល់កិច្ចដែលត្រូវបំពេញដូចជាការជ្រើសរើសមន្ត្រីបុគ្គលិកបោះឆ្នោតបំរើការងារនៅឃុំ និងការិយាល័យរៀបចំការបោះឆ្នោត ការផ្តល់បញ្ជីឈ្មោះដល់អ្នកបោះឆ្នោតផ្លូវការដល់ឃុំ ណែនាំបន្ថែមដល់ក្រុមប្រឹក្សាឃុំពីការផ្តល់ទម្រង់ ១០១៨ ជូនអ្នកបោះឆ្នោតដែលមានឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតខុសពីឯកសារបញ្ជាក់អត្តសញ្ញាណ ការផ្តល់ប័ណ្ណព័ត៌មានដល់អ្នកបោះឆ្នោតជាលើកទី២ សំរាប់ជូនដំណឹងដល់អ្នកបោះឆ្នោត ការគ្រប់គ្រង និងផ្តល់សំភារៈបរិក្ខាដល់ការិយាល័យបោះឆ្នោតឱ្យទាន់ពេលវេលា ការចុះឈ្មោះបេក្ខជន គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅតាមឃុំ ការគ្រប់គ្រងសំរបសំរួលយុទ្ធនាការឃោសនារបស់គណបក្សនយោបាយ ការបិទផ្សាយបញ្ជីទីតាំង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការ ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការបូកសរុប និងប្រកាសលទ្ធផលបណ្តោះអាសន្នតាមឃុំ និងការសំរបសំរួលដោះស្រាយរាល់បណ្តឹងផ្សេងៗឱ្យបានទាន់ពេលវេលាសមស្របតាមនីតិវិធី និងសេចក្តីណែនាំរបស់ គជប ។

ការបោះឆ្នោតត្រឹមត្រូវ សេរី និងយុត្តិធម៌អាស្រ័យលើកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងល្អរវាងមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងការចូលរួមពីគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ ជាពិសេសប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតយល់ថា ការបោះឆ្នោតមានលក្ខណៈ សេរី យុត្តិធម៌ មានតម្លាភាព និងអាចទទួលយកបាន ។

ជាការសន្និដ្ឋានរបស់លោករាល់កិច្ចដំណើរការបោះឆ្នោតក៏ដូចជាការធ្វើបច្ចុប្បន្នភាពជាប្រចាំឆ្នាំ លេខាធិការដ្ឋានរៀបចំការបោះឆ្នោតតែងតែទទួលនូវកិច្ចសហប្រតិបត្តិការ និងជួយជ្រោមជ្រែងពីឯកឧត្តមអភិបាលខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកំលាំងរក្សាសន្តិសុខ សណ្តាប់ធ្នាប់គ្រប់ឋានានុក្រម គណបក្សនយោបាយ និងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ គឺធ្វើឱ្យយើងទទួលបានជោគជ័យ ហើយពុំមានភាពមិនប្រក្រតីណាមួយកើតឡើងគួរឱ្យកត់សម្គាល់ឡើយ ។

ទន្ទឹមនិងនេះលេខាធិការដ្ឋានក៏មានជួបការលំបាកខ្លះៗក្នុងពេលធ្វើបច្ចុប្បន្នភាពបញ្ជីប្រចាំឆ្នាំ ២០០៦ កន្លងមកនេះ ដោយស្មៀនឃុំមួយចំនួនថ្មី មានការយល់ដឹងពីនីតិវិធីនៃការចុះឈ្មោះនៅមានកំរិតទាប ធ្វើឱ្យមានកំហុសខុសឆ្គងផ្នែកបច្ចេកទេស ។ មានក្រុមប្រឹក្សាឃុំ និងគណបក្សមួយចំនួនតូចមានការភាន់ច្រឡំខ្វែងគំនិត ដែលធ្វើឱ្យមានទំនាស់បន្តិចបន្តួច ប៉ុន្តែលេខាធិការដ្ឋានខេត្តក៏

បានចុះធ្វើការសំរបសំរួលរួចរាល់ហើយ ។ មានការយឺតយាវក្នុងការប្រគល់ទម្រង់ ១០២២ និងទម្រង់បែបបទផ្សេងៗទៀតសំរាប់បំរើការឱ្យការធ្វើបច្ចុប្បន្នភាពបញ្ជីឆ្នាំនេះមិនទាន់ពេលវេលា ដោយមូលហេតុមកពីការចុះឈ្មោះលើសផែនការដែលបានកំណត់ ។ ការយកព័ត៌មាន និងការបញ្ជូនព័ត៌មានពីខេត្តទៅឃុំ ពីឃុំទៅខេត្តមិនទាន់ពេលវេលា និងមិនស្មើភាពគ្នា ។

ជាសំណូមពរលោកបានសុំឱ្យគណបក្សនយោបាយ អ្នកសង្កេតការណ៍ មេត្តាចាត់អ្នកដែលទទួលបានការបណ្តុះបណ្តាលឱ្យចុះអង្កេតការណ៍តាមបណ្តាលឃុំនៅរាល់ដំណាក់កាលនៃការបោះឆ្នោត និងសុំឱ្យអាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធមេត្តាជួយរក្សានូវជំហរអព្យាក្រឹត្យ ដើម្បីបញ្ចៀសនៅរាល់ការយល់ខុស ការភាន់ច្រឡំពីសំណាក់គណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងមេត្តាជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ជុំវិញការរៀបចំការបោះឆ្នោតឱ្យបានកាន់តែល្អប្រសើរ ។

ទន្ទឹមនិងនេះលេខាធិការដ្ឋានរៀបចំការបោះឆ្នោតសង្ឃឹម និងជឿជាក់ក្នុងកិច្ចដំណើរការរៀបចំការបោះឆ្នោតនៅពេលខាងមុខនឹងមានកិច្ចសហប្រតិបត្តិការ ទំនាក់ទំនងល្អប្រសើររវាងមន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាមួយនិងអាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធ គណបក្សនយោបាយ អ្នកសង្កេតការណ៍ដែលនឹងធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាពគ្មានទំនាស់នយោបាយ និងមានលទ្ធផលល្អអាចទទួលយកបាន ។

## ០៤. មតិរបស់អ្នកចូលរួម ដែលបង្ហាញអំពីការប្រឈមនានាឡាយក្នុងយន្តការរៀបចំការបោះឆ្នោត ក្នុងបរិបទខេត្តកំពង់ចាម

**លោក សយ សារឿន** អ្នកសំរបសំរួលអង្គការនិកហ្វិច បានមានប្រសាសន៍ពាក់ព័ន្ធនិងដំណើរការចុះឈ្មោះបោះឆ្នោត ដែលនៅពេលកន្លងមកមានប្រជាពលរដ្ឋរស់នៅឃុំផ្សេងទេ ក្រោយមកក៏បានផ្លាស់ប្តូរទីលំនៅមកឃុំផ្សេងមួយទៀត គឺឃុំដែលគាត់កំពុងតែចុះឈ្មោះបោះឆ្នោត ។ នៅដំណាក់កាលចុះឈ្មោះគាត់យកសៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណសំរាប់ទៅចុះ អញ្ចឹងគាត់មិនមានលក្ខខ័ណ្ឌស្របច្បាប់ ៤យ៉ាងទេ គាត់បានទៅជួបស្មៀន ហើយស្មៀនឱ្យទៅជួបមេឃុំដើម្បីបំពេញទម្រង់ ១០១៩ បញ្ជាក់ពីទីលំនៅ ។ ជាបន្តគាត់ទៅជួបស្មៀនឃុំដើម្បីធ្វើទម្រង់ ១០១៨ ដើម្បីបញ្ជាក់លក្ខខ័ណ្ឌស្របច្បាប់ ៤យ៉ាង មានសញ្ជាតិ អត្តសញ្ញាណ អាយុ និងទីលំនៅពិតប្រាកដព្រមទាំងមានបិទរូបថត ៤x៦ ចំនួន ២សន្លឹក និងមានសាក្សី ២នាក់សំរាប់ធានាអះអាង ។ ក្នុងករណីនេះលោកឃើញប្រជាពលរដ្ឋដែលទៅចុះមិនមានរូបថត ហើយស្មៀនឃុំតំរូវឱ្យរករូបថត ហើយប្រជាពលរដ្ឋមានការថុញថប់ដោយគាត់មិនមានរូបថតយកមកជាមួយហើយក៏ដើរចេញពីការិយាល័យចុះឈ្មោះបោះឆ្នោត ។ ដំណាក់កាលចុះឈ្មោះដែលឆ្នាំនេះមានរយៈពេល ២៤ថ្ងៃនេះគាត់មិនបានមកចុះឈ្មោះវិញទេ ដោយសារគាត់រករូបថតមិនបាន ព្រោះគាត់ត្រូវចំណាយលុយទៅថតរូប ត្រូវចំណាយពេលវេលាដូច្នេះគាត់បោះបង់ចោលការបោះឆ្នោតតែម្តង ។ លោកមានអនុសាសន៍ទៅលើ គជប សូមឱ្យជួយធ្វើយ៉ាងម៉េចសូមបង្កើតក្រុមការងារមួយសំរាប់ជួយថតរូបប្រជាពលរដ្ឋនៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសំរួលកិច្ចការដល់ប្រជាពលរដ្ឋ ។

ពាក់ព័ន្ធនិងរឿងបណ្តឹង ជាធម្មតាការបោះឆ្នោតតែងតែមានបណ្តឹង ហើយបណ្តឹងនេះមិនមែនតែគណបក្សនយោបាយទេដែលមានសិទ្ធិប្តឹង ប្រជាពលរដ្ឋក៏មានសិទ្ធិប្តឹងដែរ ប៉ុន្តែយើងមិនដែលបានឃើញប្រជាពលរដ្ឋណាម្នាក់ប្តឹងអំពីដំណាក់កាលចុះឈ្មោះពាក់ព័ន្ធនិងសិទ្ធិ ឬបណ្តឹងបដិសេធនណាមួយទេ ដោយសារដំណាក់កាលចុះឈ្មោះបណ្តឹងច្រើនតែនៅដៃមេឃុំ ឬស្មៀន ។ លោកបានសួរថានៅពេលដែលប្រជាពលរដ្ឋចង់ប្តឹង ហើយគាត់ទៅយកបណ្តឹងពីមេឃុំ ឬស្មៀន តើមេឃុំ ឬស្មៀនមានអារម្មណ៍យ៉ាងម៉េច? តើប្រជាពលរដ្ឋគាត់គិតថាគាត់មានការភ័យខ្លាចទេ នៅពេលដែលទៅសុំទម្រង់ ពីមេឃុំ ឬស្មៀន ។ តើខាងលេខាធិការដ្ឋានរៀបចំការបោះឆ្នោតគួរធ្វើយ៉ាងម៉េច ដើម្បីឱ្យបណ្តឹងដាច់ឆ្ងាយពីមេឃុំ ឬស្មៀន ដើម្បីឱ្យប្រជាពលរដ្ឋងាយស្រួលទៅយកបណ្តឹង ។

**លោក ឱក សេរី សោភក្តិ** បានមានប្រសាសន៍បន្ថែមជូនដល់អង្គប្រជុំថា កំលាំងយន្តការខប់សែល គឺការទទួលស្គាល់ពីគ្រប់ភាគីទាំងអស់ ដោយសារខប់សែលមានតម្លាភាព នៅពេលដែលអង្គប្រជុំមានប្រសាសន៍មក ខាងខប់សែលមិនមានការកែប្រែទេ គឺខប់សែលនិងសរសេរនៅក្នុងកំណត់ហេតុទាំងអស់ ដែលខប់សែលបានផ្ញើរកំណត់ហេតុនេះជូនទៅគ្រប់ខេត្តទាំងអស់ ថ្វាយព្រះមហាក្សត្រ ជូនទៅសម្តេចប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សម្តេចនាយករដ្ឋមន្ត្រី គណរដ្ឋមន្ត្រី និងគ្រប់ចៅហ្វាយទាំងអស់ ។ ដូច្នេះនេះគឺជាពេលសំខាន់ដែលយើងអាចបញ្ចេញមតិបាន ។

**លោក ពុធ ចេង** ជំទប់ទី២ ឃុំមៀន ស្រុកព្រៃឈរ មកពីគណបក្ស សម រង្ស៊ី បានឯកភាពលើសំដីរបស់លោកសារឿន ដែលមានប្រសាសន៍ទាក់ទងនិងទម្រង់ឯកសារដែលត្រូវប្តឹងហើយឯកសារនេះនៅមេឃុំឬស្មៀន ។ លោកក៏បានចាប់អារម្មណ៏រឿងប័ណ្ណព័តិមានកន្លងមក គឺនៅភូមិកំពង់សំណាញ់ និងភូមិព្រៃទទឹង មេភូមិគាត់ប្រមូលយកទៅ ហើយក្រុមប្រឹក្សាឃុំក៏ឱ្យទៅមេភូមិដែរ មេភូមិនិយាថាគាត់មានសិទ្ធិកែ ។ ប្រជាពលរដ្ឋថាទៅកែនៅផ្ទះមេភូមិរួចហើយ គាត់មិនបាច់ទៅកែនៅការិយាល័យសាលាឃុំទៀតទេ ជូនកាលប្រជាពលរដ្ឋមានការភាន់ច្រឡំគាត់មិនបានទៅកែទេមានករណីនេះច្រើន គាត់យល់ថាពេលទៅកែពេលភូមិសរសេរឱ្យនៅក្នុងប័ណ្ណព័តិមាន ។ ជាសំណូមពរលោកសូមឱ្យ គខប និងខាងក្រសួងមហាផ្ទៃជួយណែនាំ ឬពន្យល់ដល់មេភូមិ ឱ្យយល់ពីនីតិវិធីនៃការចែកប័ណ្ណព័តិមាន ។

**លោក ជួន ភារិទ្ធិ** តំណាងគណបក្ស សម រង្ស៊ី ស្រុកចំការលើ បានមានប្រសាសន៍ថា ពាក្យថាខប់សែលគឺជាការទប់ស្កាត់នៅយន្តការមួយកុំឱ្យមានអំពើហិង្សាក្នុងការបោះឆ្នោត តែចំពោះបុគ្គលមួយចំនួនដែលកាន់អំណាចបាននិយាយបង្អើលប្រាប់ប្រជាពលរដ្ឋថា បើមិនបោះឆ្នោតឱ្យគណបក្សរបស់គាត់ទេ នឹងកើតមានសង្គ្រាម នេះជាបញ្ហាមួយដែលប្រជាពលរដ្ឋមានការព្រួយបារម្ភណ៏ ។ បញ្ហាមួយទៀតលោកបានបញ្ជាក់ពីការពិនិត្យបញ្ជីឈ្មោះនៅស្រុកចំការ ដែលលោកបានចុះទៅផ្ទាល់មានចំនួន ៨ឃុំ ក្នុងនោះមានមេភូមិដែលក្រុមប្រឹក្សាឃុំបានចាត់តាំង តែគាត់មិនសូវយល់ពីការងារនិងការចែកប័ណ្ណព័តិមានទេ ជួនកាលគាត់យកទៅចែកឱ្យក្រុមគាត់ បក្សគាត់ លោកសង្កេតឃើញថាមានការរើសអើង ។ លោកផ្ទាល់ក៏បានធ្វើអន្តរាគមន៍ ដែលមានលោក សុខ ឈិន ជាអ្នកចងក្រងកំណត់ហេតុក្នុងការពិនិត្យប័ណ្ណព័តិមាន ។ ព្រឹត្តការណ៏នោះកើតមាននៅក្នុងឃុំស្ពឺ ក្រោយពេលដែលមានអន្តរាគមន៍ពី គខប ឃើញថាមានភាពអន់ថយ តែនៅមានបញ្ហាកែតំរូវទិន្នន័យ ។ លោកឃើញថាសៀវភៅ គជប បានឱ្យទៅកែទិន្នន័យឈ្មោះសំរាប់ដំណាក់កាលទី១ នោះគឺមិនមានប្រសិទ្ធភាពទេ មូលហេតុមេភូមិគាត់ដើរកែ ជួនកាលឈ្មោះបក្សគាត់ គឺគាត់កែទិន្នន័យបានត្រឹមត្រូវ តែលោកផ្ទាល់តំណាងឱ្យគណបក្សសមរង្ស៊ីលោកបានទិញពី គជប ដែរ ហើយបានយកទៅឱ្យមេភូមិតែគាត់អត់កែឱ្យទាំងអស់ ។

ជាក់ស្តែងនៅភូមិស្រែព្រាល ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម មេភូមិកែឱ្យក្រុមប្រឹក្សាភូមិមួយដែលក្នុងប័ណ្ណបោះឆ្នោតឈ្មោះ សៅ ឈុនលី ឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណ សៅ សុខលី គាត់មិនកែឱ្យហើយគាត់ហែកកន្ទុយសន្លឹកប័ណ្ណព័តិមានចោល នេះជាទង្វើមួយដែលខប់សែលគួរតែមានបទពិសោធន៍ ។ លោកបានសួរថាតើយើងមានវិធានការយ៉ាងដូចម្តេច ដើម្បីទប់ស្កាត់នូវរាល់សកម្មភាពជាយុទ្ធសាស្ត្រនយោបាយក្នុងការបោះឆ្នោត ។

**លោក ឱក សេរី សោភក្តិ** បានបញ្ជាក់ប្រាប់អង្គប្រជុំថា ខប់សែលនៅពេលដែលបានធ្វើកន្លងមកនៅខេត្តផ្សេងៗទៀត ពេលដែលបានទទួលដំណឹងច្បាស់ៗនៅភូមិ ខប់សែលបានធ្វើសហប្រតិបត្តិការជាមួយ គជប និងក្រសួងមហាផ្ទៃ ដើម្បីស៊ើបអង្កេតនៅកន្លែងដែលបានប្រាប់ ថារឿងនេះពិតប្រាកដមែន ឬមិនមែន ។ ដូចការដែលលោក ភារិទ្ធិ បានលើកឡើងនៅភូមិស្រែព្រាល គជប និងក្រសួង

មហាផ្ទៃត្រូវតែចុះទៅមើល បើគាត់មិនចុះទៅមើល យើងមិនបានទទួលរបាយការណ៍មកវិញ បានសេចក្តីថាមានបញ្ហាអញ្ចឹងមែន ហើយមិនព្រមកែ ។

នៅខេត្តឯទៀតបើសិនជាមានបញ្ហា គជប និងក្រសួងមហាផ្ទៃចុះទៅមើល ព្រោះបញ្ហាជួនកាលបុគ្គលនៅថ្នាក់ក្រោមគាត់ធ្វើដោយសារគាត់បានទទួលបញ្ជាពីបក្សមក គាត់ចេះតែចាត់វិធានការណ៍ខ្លួនគាត់ ទៅតាមបរិបទនៅកន្លែងគាត់ ប៉ុន្តែមិន មែនជាបញ្ហាមកច្របូកច្របល់ពេញផ្ទៃប្រទេសទេ ។ ដូច្នេះខប់សែលចង់ឱ្យមានការស៊ើបអង្កេត មានការចុះទៅកែខៃស្ថានការណ៍កន្លែងនោះ បើសិនជាមានព័ត៌មានច្បាស់ ។

កន្លងមកនៅខេត្តឯទៀត ខប់សែលបានឃើញមានការកែជាហូរហែមកហើយ ដូចជាករណីនៅប៉ូលិសយកលុយធ្វើអត្តសញ្ញាណប័ណ្ណ គឺខាងប៉ូលិសពីភ្នំពេញចុះទៅស្រាវជ្រាវមើល នៅពេលដែលខប់សែលបានបញ្ជូនព័ត៌មានទៅគាត់ ហើយគាត់បានដាក់ពិន័យ ដាក់ទោសទៅតាមអ្វីដែលគាត់បានធ្វើ ។

**លោក ឆេង សុផល** ក្រុមប្រឹក្សាឃុំសួង ស្រុកត្បូងឃ្មុំ បានសង្កេតឃើញថាទំនាស់កើតមានហើយ នៅតែកើតមានទៀតជារៀងរាល់លើក លើការអំពាវនាវអ្នកចុះឈ្មោះបោះឆ្នោត ។ នៅឆ្នាំ ២០០៣ ពេលការចុះឈ្មោះបោះឆ្នោតមកដល់ ខាង គជប តែងតែផ្តល់ព័ត៌មាន និងអំពាវនាវដល់អង្គការសង្គមស៊ីវិល គណបក្សនយោបាយ និងអ្នកពាក់ព័ន្ធដ៏ទៃទៀតឱ្យជួយសហការក្នុងការអំពាវនាវហៅប្រជាពលរដ្ឋឱ្យមកចុះឈ្មោះបោះឆ្នោត ។ គណបក្សសម រង្ស៊ីតែងតែមានសារពី ឯកឧត្តម សម រង្ស៊ី សំរាប់ធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋឱ្យទៅចុះឈ្មោះបោះឆ្នោត នៅពេលដែលចាប់ផ្តើមផ្សាយសារនេះតែងតែមានបញ្ហាចំរូងចំរាស់គ្នា ទាំងនៅឆ្នាំ ២០០៣ ហើយនៅពេលថ្មីនេះក៏មាន ។ លោកឆ្ងល់ថានៅពេលដែលមានរឿងរាវនេះកើតឡើង លោកបានសួរទៅខាងលើ គេថាគេធ្វើប្រតិភូកម្មជូនទៅក្រុមប្រឹក្សាឃុំរួចហើយ ក្រុមប្រឹក្សាឃុំបានធ្វើទៅតាមអ្វីដែលគាត់គិតថាសមស្របទៅនិងច្បាប់ ។

ជាបន្ថែមលោកបានជំរាបជូនអង្គប្រជុំថា នៅឆ្នាំ ២០០៣ លោកបានធ្វើការងារផ្សព្វផ្សាយនៅឃុំទន្លេបិទ ពេលនោះមានរឿងអាក្រក់មើល ហើយជូរជាតិជាទីបំផុត ជារូបភាពគឺដូចជាការមកប្លន់ ដកហូត រហូតដល់មានក្របួចកអាវគ្នាទៅវិញទៅមក ។ រូបលោកផ្ទាល់ជាមួយមេឃុំទន្លេបិទ ។ លោកបានសំណូមពរមកខាងខប់សែលសូមឱ្យជួយទំនាក់ទំនងជាមួយ គជប ដើម្បីធ្វើការងារនេះ ហើយចេញសេចក្តីណែនាំឱ្យច្បាស់ថា ការអំពាវនាវនេះឱ្យធ្វើរបៀបណា ឱ្យធ្វើឬមិនឱ្យធ្វើ សារនេះឱ្យចាក់ផ្សាយឬមិនឱ្យ ។ រឿងនេះមានការផ្សព្វផ្សាយដល់ថ្នាក់អន្តរជាតិ ហើយរឿងនេះកើតឡើងម្តងហើយ កើតឡើងម្តងទៀត ។ បញ្ហានេះបានធ្វើឱ្យអ្នកធ្វើការនៅខាងក្រោមទាំងអស់ពិបាក ដូចលោកក្នុងនាមក្រុមប្រឹក្សាឃុំត្រូវមានទំនាស់ជាមួយមេឃុំ ដោយសារបក្សផ្សេងគ្នា ដូច្នេះធ្វើឱ្យមានការទំនាស់មើលមុខគ្នាមិនត្រង់នៅក្នុងសង្គមខ្មែរទាំងមូល ។

**លោក ឃឹម ឈុនហុក** តំណាងគណបក្ស សម រង្ស៊ី ស្រុកស្ទឹងត្រង់ បានមានប្រសាសន៍ទាក់ទងនិងប័ណ្ណព័ត៌មាន ដែលភាគច្រើនប្រជាពលរដ្ឋគិតថាអាចយកជាការបាន ហើយគាត់មិនបានទៅកែទេ ដោយខ្វះការណែនាំពីមន្ត្រី អាជ្ញាធរមូលដ្ឋាន ។ បញ្ហាមួយទៀតនៅឃុំរាក់ត្នោត ការកែតំរូវបញ្ជីឈ្មោះមានកន្លែងខ្លះគាត់កែប៊ិចខៀវ តែនៅក្នុងនីតិវិធីឱ្យកែប៊ិចក្រហម ។ ដោយយល់ឃើញថាកន្លងមកប្រជាពលរដ្ឋខុសឈ្មោះច្រើន ហើយប្រជាពលរដ្ឋមួយចំនួនមិនទាន់បានទទួលអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទេ លោកក៏បានសំណូមទៅខាង គខប និង គជប ធ្វើការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ឱ្យគាត់បានយល់គ្រប់គ្នា ដើម្បីទៅធ្វើទម្រង់ ១០១៨ និងដើម្បីឱ្យមានសិទ្ធិបោះឆ្នោតទាំងអស់គ្នា។

**លោក ផ្លោក សុវណ្ណ** មេឃុំកំពង់ចាម គណបក្សប្រជាជនកម្ពុជា ដោយបានស្តាប់អង្គប្រជុំមានមតិ លោកសង្កេតឃើញមានបញ្ហាមួយចំនួន ប៉ុន្តែក្នុងការអនុវត្តន៍តួនាទីជាមេឃុំកន្លងមក គឺមានការខិតខំណាស់រឿងចុះឈ្មោះ មិនឱ្យមានស្ទះទេ ដោយយល់ឃើញថាលទ្ធិប្រជាធិបតេយ្យនាំមកនូវសន្តិភាព និងការអភិវឌ្ឍន៍ ។ ការដែលជាប់ឈ្មោះដោយកិត្តិយស គឺបំរើជាតិដោយកិត្តិយស បានន័យថាមានតម្លាភាព និងយុត្តិធម៌ បើគេមិនពេញចិត្តមិនបាច់ខំទេ ។ លោកនៅមិនច្បាស់និងបញ្ហាមួយចំនួន បើសិនយើងសង្កេតមើលសេចក្តីណែនាំបច្ចេកទេសក្នុងការចុះឈ្មោះបោះឆ្នោត ចំពោះកាលវិភាគនៃការចុះឈ្មោះបោះឆ្នោត មិនទាន់មានយន្តការមួយដែលឯកឧត្តម សមរង្ស៊ីមានប្រសាសន៍នៅឡើយទេ បានន័យថាគណបក្សនយោបាយមិនទាន់ឃោសនាទេ ។ លោកមិនជំទាស់ទៅនិងការអំពាវនាវរបស់ឯកឧត្តមទេ ប៉ុន្តែគ្រាន់តែទាស់ថាពេលចេញសេចក្តីផ្តើមមកថា លោកជាសមរង្ស៊ីប្រធានគណបក្ស ដូច្នេះលោកគិតថានេះមិនទាន់ដល់ពេលត្រូវចេញដំណើរទេ នេះនាំឱ្យមានបញ្ហាជំទាស់ ។ នៅមូលដ្ឋានមិនមែនមានបញ្ហានិងគ្នាទេ ទោះបីជាបក្សខុសគ្នាក៏ដោយ ព្រោះសុទ្ធតែកូនខ្មែរដូចគ្នា ប៉ុន្តែពេលមានបញ្ហាម្តងៗឈឺក្បាលទាំងអស់គ្នា ។ លោកផ្ទាល់ក្នុងមានអាជ្ញាធរដែលត្រូវតែអព្យាក្រឹត្យ ដូច្នេះទាល់តែមានច្បាប់មួយឱ្យផ្អែក ដើម្បីឱ្យអនុវត្តបានត្រឹមត្រូវ តែច្បាប់បោះឆ្នោតមិនច្បាស់ដែរ មិនមានពាក់ព័ន្ធរឿងថាគណបក្សនយោបាយត្រូវចាប់ផ្តើមឃោសនា ពីណាទៅណា ។ បើក្នុងពេលក្បួនមិនទាន់ចេញបើល្មើស តើត្រូវមានបទបញ្ញត្តិអ្វីដើម្បីឱ្យខាងលោកសំរេចចិត្តឱ្យមានអព្យាក្រឹត្យ ជាការពិតបុគ្គលម្នាក់ៗមិនដែលអព្យាក្រឹត្យទេ ប៉ុន្តែនៅក្នុងមុខងារសាធារណៈទាល់តែអព្យាក្រឹត្យ ដើម្បីអព្យាក្រឹត្យបានទាល់តែមានច្បាប់ផ្អែក ។

បញ្ហាទម្រង់ ១០១៨ ខាងលោកមិនមានបញ្ហាទេ ទោះបីមិនមានរូបថតក៏ឱ្យជំពាក់ដែរ ពេលណាដែលមានរូបថតមកបិទបានលោកនឹងវាយត្រាឱ្យ ។

ចំពោះបញ្ហាបណ្តឹង ១០២២ ពាក្យបណ្តឹងនេះគឺគេប្តឹងទៅស្មៀឃុំ ព្រោះគាត់ជាអ្នកបដិសេធនមិនឱ្យចុះឈ្មោះ ហើយអំណាចមិនមែនធំត្រឹមមេឃុំទេ គឺក្រុមប្រឹក្សាឃុំជាអ្នកកាត់ក្តី ជាអ្នកសំរេចថាត្រូវលុបឈ្មោះ ឬចុះឈ្មោះ មិនមែនមេឃុំតែម្នាក់ទេ ព្រោះក្នុងឃុំមានក្រុមប្រឹក្សាឃុំចំណុះបក្ស ហើយនៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោតមានចាត់តាំងតំណាងគ្រប់ភាគីក្រុមប្រឹក្សាឃុំត្រួតពិនិត្យទៀត ។

បញ្ហាប័ណ្ណព័តិមាន តាមការពិតមេភូមិមានប្រាក់ខែ ២២ ០០០រៀល គាត់មិនចង់ធ្វើទេ តែនេះជាភារកិច្ចគាត់ត្រូវតែដើរចែក ហើយលោកក៏មានក្រុមការងារដែលជាតំណាងក្រុមប្រឹក្សាឃុំ គណបក្សនយោបាយចុះទៅជាមួយដែរ ។

លោកក៏សូមសំណូមពរទៅខាង គជប ចំពោះការផ្សព្វផ្សាយ ព្រោះថវិការដែល គជប ផ្តល់ ៥ម៉ឺនរៀលតិចពេក ព្រោះបើជួលមេក្រូ១ថ្ងៃ ២ម៉ឺន ចុះបើ ៣ថ្ងៃ ៦ម៉ឺន ។ ខាងលោកបានចំណាយលុយឃុំជួយធ្វើជាខិតប័ណ្ណសំរាប់អំពាវនាវឱ្យប្រជាពលរដ្ឋមកចុះឈ្មោះ ហើយដាក់កាលវិភាគប្រាប់គាត់ថា នៅថ្ងៃនេះកន្លែងនេះរហូតដល់ចប់ ។ ពេលចែកលោកមិនបានឱ្យខាងមេភូមិចែកទេ ខាងលោកបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលក្នុងនោះក្រុមប្រឹក្សាយុវជនកម្ពុជា ក្នុងការជួយដើរចែក ព្រោះកំលាំងខាងគាត់អព្យាក្រឹត្យ ហើយចែកគ្រប់គ្រួសារ ។

**លោក ណុប យូស្រេង** ក្រុមប្រឹក្សាឃុំគងជ័យ ស្រុកអូរាំងឪ គណបក្សប្រជាជនកម្ពុជា បានយល់ស្របជាមួយប្រសាសន៍របស់លោក សោភក្តិ៍ ដែលជាជំហរមួយល្អណាស់ ព្រោះក្នុងនាមជាប្រជាជនខ្មែរ មានឈាមជាខ្មែរ យើងគ្រប់គ្នាបានឆ្លងកាត់ឧបសគ្គមកច្រើនហើយ អញ្ចឹងយើងចង់ឱ្យប្រទេសយើងមានសភាពការល្អ នោះយើងត្រូវមានយន្តការសំរាប់បង្ការទំនាស់ ។ នៅឃុំគងជ័យ ស្រុកអូរាំងឪ មានគណបក្សនយោបាយមួយគាត់យកកាសែតដែលចាក់អំពាវនាវឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះ និងកែទិន្នន័យ កន្លងមក

លោកបានស្តាប់ន័យខាងដើមខ្លឹមសារទៅតាម គជប ប៉ុន្តែចុងក្រោយមានពាក្យដកខាងនេះខាងនោះ លោកក៏ឱ្យសមត្ថកិច្ចទៅឃាត់មើលថាខ្លឹមសារនៃការយុទ្ធនាការឃោសនាការដល់ហើយឬនៅ ។ ក្នុងនាមលោកជាប្រជាពលរដ្ឋបើឃើញមានអ្វីខុសបន្តិចបន្តួច លោកត្រូវតែប្រឹងកែលំអគ្នា មិនមែនឃើញខុសហើយយកបញ្ហានេះទៅពង្រីកឱ្យកាន់តែធំទៀតទេ ។

**ព្រះតេជគុណ ថន វណ្ណុង** ប្រធាន សមាគមនអភិវឌ្ឍន៍ពុទ្ធសាសនា និងសង្គម (BSDA) អ្វីដែលព្រះអង្គបានចាប់អារម្មណ៍ គឺមកពីមនុស្សមានមហិច្ឆិតា បើសិនជាមនុស្សបន្ថយមហិច្ឆិតានៃការចង់បាន ការលោភលន់ ប្រហែលជាទំនាស់នឹងថយមកវិញ បើគិតតាមធម៌ព្រះ ។ ជាតំណាងឱ្យប្រជាពលរដ្ឋ ហើយក្នុងនាមព្រះអង្គជាព្រះសង្ឃត្រូវមានអព្យាក្រឹត្យ មិនមាននិន្នាការនយោបាយទេ ។

ព្រះតេជគុណបានលើកឡើងនៅសំណួរ ២

**ទី១** ប្រជាជនទូទៅបានត្អូញត្អែរថា មិនដឹងជាទៅចុះឈ្មោះបោះឆ្នោតធ្វើអីទេ គេជាប់តែគ្នាគេ ។ តើយើងអាចមានដំណោះស្រាយណាមួយដែលអាចពន្យល់ប្រជាជនថា គាត់ត្រូវតែបញ្ចេញនៅការគាំទ្ររបស់គាត់ទៅលើគណបក្សណាមួយលើឆន្ទះរបស់គាត់ ដើម្បីឱ្យគណបក្សនោះមកបំរើផលប្រយោជន៍រួមរបស់យើងវិញ ។

**ទី២** ទាក់ទិននិងយុវជនភាគច្រើនមិនចាប់អារម្មណ៍រឿងការចុះឈ្មោះបោះឆ្នោតទេ ដូចជាក្មេងដែលស្នាក់នៅវត្ត សូម្បីតែមានការចែកខិតប័ណ្ណក៏គេមិនដែលមានគំនិតថានឹងទៅស្រុក ដើម្បីទៅចុះឈ្មោះបោះឆ្នោត ។ ដូច្នេះយើងគួរតែមានការផ្សព្វផ្សាយណាដែលទូលំទូលាយជាងនេះទៀត ។

ដោយព្រះអង្គបានស្តាប់វិទ្យុអាស៊ីសេរី ហើយខាងខុមហ្វ្រែលបានផ្សព្វផ្សាយថាមានការចុះឈ្មោះខ្មោច ដោយមិនយល់អំពីរឿងនេះព្រះអង្គក៏បានសូមឱ្យខាង គខប ឬខប់សែល ពន្យល់ពីរឿងនេះ ។ បើសិនជាមានរឿងនេះមែន ហើយមានច្រើន តើជាឧបសគ្គដល់កម្មវិធីបោះឆ្នោតដែលឬទេ? ព្រោះកាលឆ្នាំ ២០០៣ មានតែ២០% ឥឡូវឡើងដល់ ៤០% ។

**លោក លឹម ប៉ូលី** តំណាងគណបក្ស សម រង្ស៊ី ស្រុកកំពង់សៀម បានឯកភាពនិងប្រសាសន៍របស់លោក យូស្រេង ដែលថាយើងជាជាតិខ្មែរ មានឈាមខ្មែរ លោកសូមស្វាគមន៍នៅពាក្យនេះ ។ លោកបានលើកពីបញ្ហានៅឃុំកោះរការមុនថ្ងៃទី ០៨ ដែលលោកមេឃុំ និងស្មៀន ពុំចុះឈ្មោះឱ្យប្រជាពលរដ្ឋដែលមិនមានអត្តសញ្ញាណប័ណ្ណសំរាប់បោះឆ្នោត នៅក្នុងទម្រង់ ១០១៨ ។ ចំពោះប្រជាពលរដ្ឋដែលមិនមានរូបថតគឺមិនចុះឱ្យទេ លោកបានប្រាប់ថាខាងលេខាធិការដ្ឋានបានជូនដំណឹងថាអាចជំពាក់រូបថតបាន គាត់ឆ្លើយមកវិញថា លេខាធិការដ្ឋានមិនបានបញ្ជូនមកទេ លោកនិយាយហេតុអ្វីនៅឃុំគគរគេអាចចុះបាន គាត់ថាគគរជិះយន្តហោះមកឬជិះម៉ូតូតាមដីកោះរការ ចំណុចនេះធ្វើឱ្យមានបញ្ហាបន្តិច ។ លោកសូមសួរទៅខាងលេខាធិការដ្ឋានថា តើបានបញ្ជូនហើយ ឬមិនបញ្ជូន? ។

ចំណុចមួយទៀតនៅភូមិស្រល់ ឃុំស្រក ថ្មីៗនេះមានស្មៀនឃុំ និងជំទប់ទី២ មិនព្រមបិទរូបថតចាស់លើទម្រង់ ១០១៨ ឱ្យប្រជាពលរដ្ឋទេ គាត់ទាមទារប្រជាពលរដ្ឋចំនួនក្រោម ១០០នាក់ ទៅថតរូបថតថ្មី ទើបគាត់បិទឱ្យ ដោយមានការប្រកាន់បក្សពួក ។ ការថតរូបថតថ្មីត្រូវចំណាយលុយ ២ ០០០រៀល បញ្ហានេះមានធ្វើឱ្យមានអំពើហិង្សាលើគ្រួសារមួយ ប្តីបានវាយប្រពន្ធ ពេលដែលប្រពន្ធចំណាយលុយ ២ ០០០ រៀល សំរាប់ថតរូប ប្តីនិយាយថារូបថតមានហើយម៉េចក៏មិនបិទ លុយ ២ ០០០ រៀលមិនងាយរកបានទេ ប្រពន្ធតបទៅវិញថាបិទយ៉ាងម៉េចបើស្មៀនគេមិនព្រមបិទឱ្យ ។ លោកបានសំណូមពរទៅខាងលេខាធិការដ្ឋានធ្វើយ៉ាងម៉េចឱ្យប្រជាពលរដ្ឋចំនួនក្រោម ១០០នាក់ បិទរូបថតឱ្យបានសំរាប់ធ្វើទម្រង់ ១០១៨ ហើយឱ្យស្មៀនទៅធ្វើដល់ភូមិនោះតែម្តង ព្រោះពីភូមិទៅសាលាឃុំមានចំងាយ ១០km បញ្ហានេះធ្វើឱ្យប្រជាជនលែងមានជំនឿលើការចុះឈ្មោះ ។

**លោក ឈួន យុគ** ជំទប់ទី២ ឃុំកោះទន្ទឹម គណបក្សហ៊្វុនស៊ិនប៉ិច បានឆ្លល់ថា ហេតុដូចម្ដេចបានជាដូរពីប័ណ្ណបោះឆ្នោត មកអត្តសញ្ញាណប័ណ្ណវិញ ។ យើងឃើញថាការធ្វើប័ណ្ណបោះឆ្នោតមានតាំងពីគណបក្សនយោបាយ មានសង្គមស៊ីវិល ពិនិត្យមើល ប៉ុន្តែធ្វើអត្តសញ្ញាណប័ណ្ណមិនមាននរណាជួយពិនិត្យទេ មានតែប៉ូលីស ។ លោកយល់ឃើញថាការទាមទារដូរនេះធ្វើឱ្យពិបាកខ្លួនឯងវិញ ។

នៅឃុំកោះទន្ទឹមធ្លាប់មានជនជាតិវៀតណាមមិនមានឯកសារអ្វីទេ តែគេមានប័ណ្ណបោះឆ្នោត គេទៅសុំកែ ហើយខាងគណបក្ស សមរង្ស៊ីបានផ្ដិតមេដៃចេញទម្រង់ ១០១៨ ឱ្យ ។ ក្រោយពេលចេញឱ្យរួចហើយគេយកទៅផ្ទះគេ ស្រាប់តែគាត់ប្ដឹងគេថាជនជាតិយួន លោកក៏ប្រាប់ថាបើដឹងថាជនជាតិយួន ហេតុអ្វីបានជាផ្ដិតមេដៃធ្វើជាសាក្សីឱ្យគេលើទម្រង់ ១០១៨ ហើយចោទគេ ។ ពេលនោះក៏មានការភ័យហើយឱ្យលោកផ្ទាល់ជួយដោះស្រាយ ។ លោកស្គាល់ម្នាក់នោះថាជាជនជាតិយួន ព្រោះកាលធ្វើបញ្ជីជាតិគេបានមកសុំលោកឱ្យធ្វើឱ្យ តែលោកមិនព្រមធ្វើឱ្យទេ ព្រោះគាត់មិនមានឯកសារអ្វីទេ គឺមានតែប័ណ្ណបោះឆ្នោតយកមកឱ្យ លោកក៏បានសួរថាអ្នកណាជាអ្នកធ្វើប័ណ្ណបោះឆ្នោតឱ្យ ដោយមិនមានការឆ្លើយតប ក៏ទៅបាត់ ។ ស្រាប់តែពេលកែឈ្មោះបោះឆ្នោតឃើញមកទៀត យកប័ណ្ណបោះឆ្នោតដដែលមកកែ លោកក៏ថាមិនបានទេ ។

រឿងមួយទៀតលោកចង់ឱ្យឯកភាពលើបញ្ជីបោះឆ្នោតមួយ មិនចង់ឱ្យមានការកែរញ៉េរញ៉ៃពីមួយទៅមួយ ឥឡូវយើងបានធ្វើអត្រានុកូលដ្ឋានពេញទូទាំងប្រទេសហើយ គួរតែឯកភាពយកធ្វើជាបញ្ជីជាតិតែមួយ ព្រោះអត្តសញ្ញាណប័ណ្ណខ្មែរយើងមានកាតសិស្ស មានបញ្ជីជាតិ មានសៀវភៅគ្រួសារច្រើនណាស់ តែថ្ងៃខែមិនដែលត្រូវគ្នាទេ ។

**លោក ឱក សេរី សោភក្តិ** បានមានប្រសាសន៍ថា ដោយមិនមានតំណាងខាងខុមហ្វ្រែលមកចូលរួម លោកអាចបញ្ជាក់បានខ្លះទាក់ទងនិងរឿងឈ្មោះខ្មោច ដែលជាចម្ងល់របស់ព្រះតេជគុណ ថន វណ្ណុង តាមដែលលោកបានឮហៅថាឈ្មោះខ្មោចនេះក៏មិនប្រាកដជាត្រូវដែរ មិនដែលថាអត់មនុស្សហើយទៅចុះឈ្មោះកើតទេ ប៉ុន្តែបើមានឈ្មោះហើយគាត់មិននៅ គាត់បានចំណាកស្រុកដោយសារហេតុផលសេដ្ឋកិច្ច ឬរកគាត់មិនឃើញពេលដែលចុះ ហើយគាត់មិនបានទៅមើលក៏ជារឿងផ្សេងទៀត ។ ជួលកាលគាត់ប្ដូរអាសយដ្ឋានហើយប្ដូរពីកន្លែងមួយទៅកន្លែងមួយហើយមានស្ទួន នេះយើងអាចលុបចោលបាន ដូចកាលដែលលុបចោលចំនួន ១០ ០៩ នាក់ ។ ដូច្នេះការដែលប្រើឈ្មោះខ្មោចទាល់តែយើងប្រើនិយមន័យឱ្យត្រូវគ្នា បើដូចនៅក្នុងកងទ័ពមានឈ្មោះ តែមិនមានមនុស្ស ហើយបើមានអ្នកមកបើប្រាក់ខែជំនួសយើងអាចហៅបាន ។

**លោក មាង ម៉េងហ៊ួន** បានឆ្លើយនូវសំណួរ និងសំណូមពររបស់អង្គប្រជុំជាសរុប

**ទី១** ចំពោះការចុះឈ្មោះ នៅឆ្នាំ ២០០៤ ក្រោយពីមានការប្រតិភូកម្មអំណាចជូនក្រុមប្រឹក្សាឃុំ អញ្ចឹងអំណាចបានផ្ទេរទៅឱ្យឃុំ និងស្មៀនជាមន្ត្រីចុះឈ្មោះ ។ អាជ្ញាធរដែនដីឃុំគាត់ជាមន្ត្រីចុះឈ្មោះផង ជាអាជ្ញាធរដែនដីផង អញ្ចឹងបើមន្ត្រីស្មៀនធ្វើខុសយើងប្ដឹងមេឃុំ បើសិនជាមេឃុំធ្វើខុស យើងប្ដឹងអាជ្ញាធរស្រុករហូតដល់ខេត្ត ។ ក្នុងន័យការងារចុះឈ្មោះ មនុស្សម្នាក់ដែលចុះឈ្មោះទាល់តែមិនមានអីសោះ តែគេមានសាក្សី ហើយសាក្សីនោះទាល់តែមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត នេះចំពោះទម្រង់ ១០១៨ ។ នៅពេលដែលចុះឈ្មោះ នៅការិយាល័យចុះឈ្មោះ នៅសាលាឃុំ នៅការិយាល័យចល័តក្ដី គឺមានគណបក្សនយោបាយជាអ្នកសង្កេតការណ៍ជាពិសេសគណបក្សធំៗទាំងបី ទន្ទឹមនិងនេះក៏មានអង្គការក្រៅរដ្ឋាភិបាល ដូចជាខុមហ្វ្រែល និកហ្វិច ក្រុមប្រឹក្សាយុវជន និងអង្គការមួយចំនួនទៀត ។ បើមានបុគ្គលម្នាក់ទៅចុះឈ្មោះ រវាងស្មៀន និងបុគ្គលម្នាក់នោះមិនអាចទៅកន្លែងណាមួយចុះឈ្មោះបានទេព្រោះតែចប់ការងារបញ្ជីនេះគេបូកសរុបនៅពេលល្ងាច ។ ចំពោះអ្នកចុះឈ្មោះបានត្រូវមានអត្តសញ្ញាណ ៤យ៉ាង បើថាស្មៀនទៅចុះឈ្មោះនៅទីណាតែពីរនាក់ តាមយោបល់លោកគិតថាគ្មានទេ ។

**ទី២** ការផ្តល់ប័ណ្ណព័ត៌មាន តាមសង្កេតឃើញនៅស្រុកចំការលើ លោកបានឱ្យអនុប្រធានលេខាធិការដ្ឋានចុះទៅសំរបសំរួលភ្លាមលើករណីនេះ ដោយមិនមានការព្រងើយកន្តើយឡើយជាក់ស្តែងនៅឃុំដា ខាងលោកចុះទៅសំរបសំរួល ស្វែងយល់អំពីកំហុសពីមូលហេតុនៃទំនាស់ តើកើតមកពីរឿងអ្វី ដើម្បីសំរបសំរួលធ្វើឱ្យការងារចុះឈ្មោះទទួលបានលទ្ធផលល្អ ។

**ទី៣** រឿងទម្រង់ ១០១៨ ដែលស្មៀនមិនព្រមបិទរូបថត លោកបានមានប្រសាសន៍ថា សេចក្តីណែនាំរបស់ គជប អាចឱ្យជំពាក់រូបថតបាន ទម្រង់ ១០១៨ អាចធ្វើបានបើរូបថតគាត់មិនទាន់មានថ្ងៃនេះ តែមុនថ្ងៃបោះឆ្នោតអាចយករូបថតទៅសងបាន ។ ចំពោះបញ្ហាដែលលើកឡើងថា តើការផ្សព្វផ្សាយដល់ដែរឬទេ ដូចតាមរបាយការណ៍ដែលលោកបានជំរាបជូនអង្គប្រជុំហើយ ថាការផ្តល់ព័ត៌មាន និងយកព័ត៌មានពីឃុំមកខេត្ត ពីខេត្តទៅឃុំគឺមានផលលំបាកណាស់ ។ ជាក់ស្តែងនៅឃុំកោះរការ ឃុំកោះទន្ទឹម ឆ្នាំនេះនៅខេត្តកំពង់ចាមមានទឹកជំនន់ពីរដង ហើយចំពេលវេលាដែលចុះឈ្មោះ នាំក្រុមប្រឹក្សាឃុំ ស្មៀនឃុំជួបការលំបាកណាស់ក្នុងការធ្វើដំណើរ ហើយការផ្តល់ប័ណ្ណព័ត៌មានគាត់បានលុយទឹក ម្តងជាពីរដងមិនជួប ណាមួយមានភ្លៀងទៀត អញ្ចឹងសូមអស់លោកអធ្យាស្រ័យ និងយោគយល់ បើសិនជាមានការខុសឆ្គងបន្តិចបន្តួច។

**ទី៤** ការឃោសនា តែងតែមានការខុសឆ្គង ហើយអង្គប្រជុំសួរថាមិនដឹងជាទៅសួរខាងណា ជាការឆ្លើយតបលោកថា សារាចរណែនាំរួមលេខ ០១១ ស្តីពីលេខាធិការដ្ឋាន គឺជាអ្នកសំរបសំរួល និងសហការណ៍អនុវត្តន ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត ។ ដូច្នេះលេខាធិការដ្ឋានគ្រាន់តែ ជាអ្នកនាំពាក្យ ឬនាំឯកសារពី គជប ជូនឃុំតែប៉ុណ្ណោះ បើសិនជាមានបញ្ហាលេខាធិការដ្ឋានចុះទៅសំរបសំរួលភ្លាម រកហេតុផលខុសត្រូវ បើសាម៉ីភាគីខាងណាមួយមិនសុខចិត្តអាចប្តឹងទៅ គជប បន្ត ឬតាមឋានានុក្រម ។

**ទី៥** ជាសំណូមពរដែលថាឱ្យ គជប ធ្វើច្បាប់ ឬបញ្ជីអ្នកបោះឆ្នោះឱ្យមានការឯកភាព បើតាមរបាយការណ៍ដែលលោកបានជំរាបជូនអង្គប្រជុំថា ការងារ នីតិវិធីចុះឈ្មោះ នីតិវិធីបោះឆ្នោតក្តី គឺយកឆ្លងតាមអនុសាសន៍របស់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ដើម្បីកែសំរួល ហើយបានកែសំរួលជាបណ្តើរៗហើយ បញ្ជីចុះឈ្មោះបោះឆ្នោតនៅពេលខាងមុខបន្តិចនឹងកាន់តែសុក្រឹត ។ ដោយពិនិត្យជារួម លោកបានជំរាបជូនថាឧបមាលុបឈ្មោះ ក ដែលខុស ព្រោះឥឡូវគេប្រើកុំព្យូទ័រដែលមានអក្ខរក្រមជាអក្សរខ្មែរ បើយើងរកឈ្មោះ ក គឺវារត់ទៅលើម៉្ក ក ដូចគ្នា ហើយបើមានឈ្មោះ ក និងថ្ងៃខែឆ្នាំកំណើតដដែល បានន័យថានេះជាឈ្មោះស្ទួន ដូចលោកសោភក្តិបានជំរាបជូនកាលដែលលុប ក្នុងករណីនេះមានអ្នកស្លាប់ អ្នកផ្លាស់ចេញ និងឈ្មោះស្ទួន ។

នៅជំហានដំបូងយើងឃើញស្រាប់ហើយ ការចុះឈ្មោះនៅឆ្នាំ២០០២-២០០៣ មានមន្ត្រីមួយក្រុមសំរាប់ចុះឈ្មោះ ហើយត្រូវចំណាយថវិការយ៉ាងច្រើន ឥឡូវយើងឈានដល់ការចុះឈ្មោះ និងបោះឆ្នោតដោយខ្លួនឯង ត្រូវផ្អែកទៅលើថវិការ អញ្ចឹងហើយបានជារាជរដ្ឋាភិបាលធ្វើប្រតិភូកម្មអំណាចមួយជូនទៅក្រុមប្រឹក្សាឃុំ ដើម្បីឱ្យគាត់ក្តាប់បានថា ប្រជាជនផ្លាស់ចេញ ឬឈ្មោះស្ទួនហើយនៅប៉ុន្មាន ។ បើតាមលោកដឹងខាងនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃកំពុងតែធ្វើពីរឿងនេះ ព្រោះស្ថិតិត្រូវទាំងអស់ហើយ ហើយថ្ងៃណាគាត់នឹងមានកូនប៉ុន្មាន ៥នាក់ អាយុ១៨ប៉ុន្មាននាក់ ក្រសួងនឹងចេញព័ត៌មានមកឱ្យ ប៉ុន្តែយើងធ្វើមិនទាន់ដល់ចំណុចនេះនៅឡើយទេ យើងកំពុងតែរៀបចំ ។

ដូច្នេះចំពោះការខុសឆ្គងលើ ការចុះឈ្មោះ ការផ្តល់ព័ត៌មាន ការឃោសនា សូមយើងមេត្តាយោគយល់ និងអព្យាស្រ័យ ធ្វើយ៉ាងណាកាត់បន្ថយទំនាស់ឱ្យបាន ។

**លោក ឱក សេរី សោភក្តិ** បានជំរាបអង្គប្រជុំពីបញ្ហាដែលប្រជាពលរដ្ឋមានមតិថាបោះឆ្នោតធ្វើអី បើបោះឱ្យហើយអ្នកជាប់ដដែលៗ មតិនេះតាមខេត្តដែលខប់សែលបានឆ្លងកាត់មកក៏មានឮដែរ ប៉ុន្តែបើសិនយើងមើលស្ថានការណ៍កាលពីឆ្នាំ២០០៣ នៅទីក្រុង

ភ្នំពេញគណបក្សសមរង្ស៊ីជាប់លេខ១ តោងតែយើងវិភាគថាស្ថានការណ៍អ្វីក៏ដោយតែងតែមានការវិវឌ្ឍន៍ បើគណបក្សប្រជាជនចង់បានលេខ ១ វិញនៅភ្នំពេញ តោងតែគណបក្សប្រជាជនធ្វើការវិភាគមើលថា ហេតុអីបានជាធ្លាក់ពីលេខ១ មកលេខ២ ហើយកែខៃស្ថានការណ៍ ទៅតាមហ្នឹង ។ ឥឡូវគណបក្សសមរង្ស៊ីធ្វើវិភាគ ហើយកំពុងតែកែខៃស្ថានការណ៍វិញហើយ ដើម្បីដណ្តើមយកលេខ១ ។ នេះហើយជាលទ្ធិប្រជាធិបតេយ្យ ធ្វើយ៉ាងម៉េចយកចិត្តប្រជាពលរដ្ឋ ។ បើថាប្រជាពលរដ្ឋកំពុងតែគិតបែបនេះ យើងធ្វើម៉េចដើម្បីពន្យល់ប្រជាពលរដ្ឋថាការគិតបែបនេះត្រឹមត្រូវហើយ ប៉ុន្តែប្រជាពលរដ្ឋពីមួយឆ្នាំទៅមួយឆ្នាំ អ្នកដែលមានអាយុគ្រប់ ១៨ឆ្នាំកាន់តែកើនឡើង ស្របពេលជាមួយអ្នកដែលមានចំណេះវិជ្ជា អ្នកដែលយល់ដឹងពីលទ្ធិប្រជាធិបតេយ្យកាន់តែកើនឡើងដែរ ។ ដូច្នេះការពិចារណាការសំរេចចិត្តក្នុងការបោះឆ្នោតមិននៅដដែលទេ តែងតែមានការវិវឌ្ឍន៍រហូត ប្រទេសណាក៏ដូចប្រទេសណាដែរ ។

ចំពោះរឿងយុវជន មានអង្គការយុវជនច្រើនណាស់ឥឡូវដែលកំពុងតែចុះបំរើដោយស្ម័គ្រចិត្តនៅតាមសហគមន៍ ដើម្បីនិងរៀបចំក្លឹប ឬសមាគមយុវជននៅតាមសហគមន៍ ។ មានតែយុវជនទេដែលយល់ពីបញ្ហាយុវជនខ្លួនឯង អញ្ចឹងហើយបានជាកំពុងតែសស្រាក់សស្រាំណាស់ មានយុវជនមកពីភ្នំពេញចុះទៅគេងនៅតាមខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តផ្សេងនៅភាគខាងជើងក៏មានគឺ រាប់អាទិត្យ រាប់ខែ រហូតដល់ឆ្នាំ ។វិទ្យាស្ថាន CDRI ក៏មានធ្វើការជាមួយយុវជនដែរ ។

ចំពោះរឿងមេភូមិ កាលពីខែសីហា យើងចែកប័ណ្ណព័ត៌មាន យើងមើលឃើញការខ្វះចន្លោះរបស់មេភូមិថាមានការរើសអើង យើងនាំគ្នាជួយគាត់ទៅ ដល់ពេលចែកលើកក្រោយ ព្រោះ គជប មានគំរោងចែកប័ណ្ណព័ត៌មានម្តងទៀត ពេលដែលខិតជិតទៅដល់ការបោះឆ្នោត ។ យើងឱ្យខាងសង្គមស៊ីវិលធ្វើការជាមួយគាត់ ដោយឱ្យយុវជនស្ម័គ្រចិត្តចុះទៅធ្វើការជាមួយ បើយើងមិនទុកចិត្តភ្នែកមេភូមិ ថាជាគណបក្សនេះឬគណបក្សនោះ យើងផ្គួបគាត់ទៅជាមួយ ។ គជប រកមធ្យោបាយយ៉ាងម៉េច ដើម្បីបើកជំហរយន្តការនេះឱ្យមានតម្លាភាព លោកគិតថាមិនមានបញ្ហាអ្វីដែលយើងមិនអាចរកដំណោះស្រាយមិនបានទេ ឱ្យតែយើងមានសុឆន្ទះដើម្បីនឹងធ្វើការជាមួយគ្នាមែន ហើយខប់សែលបានស្តាប់បញ្ហាអញ្ចឹង បើស្តាប់បានមកហើយយើងនឹងធ្វើការរកដំណោះស្រាយរួមគ្នាទាំងអស់មិនអាចធ្វើអ្វីដែលល្អគ្រប់យ៉ាងទេ ។

ប្រទេសអូស្ត្រាលី អាមេរិច បារាំង រាប់រយឆ្នាំទំរាំតែរកលទ្ធិប្រជាធិបតេយ្យបាន ហើយកម្ពុជាទើបតែ ៨ឆ្នាំធ្វើបាន ប៉ុណ្ណឹងឱ្យយើងទម្លាប់មើលឃើញអ្វីដែលជាវិជ្ជមាន អ្វីដែលសមិទ្ធិផលរួមរបស់ប្រជាពលរដ្ឋខ្មែរ កន្លែងណាដែលនៅខ្វះចន្លោះយើងត្រូវនាំគ្នាកែ ប៉ុន្តែឱ្យមានការជជែកទល់មុខគ្នានៅលើតុបែបនេះ ទើបយើងឃើញបញ្ហាដែលខ្វះចន្លោះយើងកែ១ យូរ១ទៅនឹងសុក្រឹត្យ ។ កាលយន្តការបោះឆ្នោតនៅឆ្នាំ ១៩៩៨ និង ២០០២ គ្រាន់តែពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត យើងចំណាយ ៤លានដុល្លា ឥឡូវយើងកាត់បន្ថយ តែយើងនូវតែបានយន្តការមួយដែលអាចទទួលយកបាន ។ ដូច្នេះមិនមានបញ្ហាណាដែលយើងដោះស្រាយមិនបាន បើសិនយើងស្ម័គ្រចិត្តដោះស្រាយរួមគ្នា ។

**លោក សេក សណ្តាប់** ប្រធានក្រុមប្រឹក្សាឃុំ ស្រុកកោះសូទិន គណបក្ស សមរង្ស៊ី ចំពោះការចាក់ផ្សាយរបស់គណបក្សសមរង្ស៊ីកន្លងមកយើងរង់ចាំមើលការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះនៅតាមឃុំនីមួយ១ ប៉ុន្តែការធ្វើមិនមានមនុស្សចូលរួមច្រើនកុះករ ដូចជាលទ្ធផលថ្មី១នេះ ដែលខាងលេខាធិការដ្ឋានបញ្ជាក់ថាបានតែ ៦០% នៅសល់៤០%ទៀត ។ តើយើងមានជំនឿថា ៤០% នេះមានឈ្មោះត្រូវនិងបញ្ជីរបស់យើងដែលឬទេ បើមិនត្រូវតើយករកវិធីណាឱ្យប្រជាពលរដ្ឋនោះមានសិទ្ធិទៅបោះឆ្នោតនៅក្នុងពេលខាងមុខ ។

មានបញ្ហាមួយនៅក្នុងឃុំមហាលាភ ស្រុកកោះសូទិន អាជ្ញាធរគាត់មានសិទ្ធិទៅដកយកឯកសាររបស់គណបក្សនយោបាយ បើតាមការពិត គជប ឬមេឃុំដកមិនមានបញ្ហាទេ ប៉ុន្តែនេះអាជ្ញាធរគាត់ដក ហើយយើងទាមទារតែឯកសារមួយបញ្ជាក់ថាគាត់បានដក ក៏គាត់មិនឱ្យដែរ ។ លោកបានសំណូមពរឱ្យអាជ្ញាធរធ្វើខ្លួនឱ្យមានការអព្យាក្រឹត្យ ។

លោកបានសួរទៅខាងលេខាធិការដ្ឋានខេត្តធ្វើយ៉ាងណាចំពោះមនុស្ស៤០%ទៀត ដើម្បីឱ្យគាត់មានសិទ្ធិមកបោះឆ្នោតបាន ។

**លោក មាង ម៉េងហ៊ួន** បានជំរាបថា ៤០%នេះគឺការផ្តល់ប័ណ្ណព័ត៌មានលើកទី១ មិនមែនការងារចុះឈ្មោះទេ ហើយការដែលនៅសល់៤០%យើងប្រគល់ឱ្យស្មៀនឃុំ ដើម្បីឱ្យប្រជាពលរដ្ឋដែលមិនទាន់បានទទួលគាត់មកពិនិត្យនិងយក បើត្រូវនិងអត្តសញ្ញាណប័ណ្ណ ឬឯកសារបញ្ជាក់សញ្ជាតិរបស់គាត់ ការធ្វើនេះដើម្បីជួយសំរួលការងារដល់ស្មៀនឃុំក្នុងការពិនិត្យបញ្ជីឈ្មោះ ។

ចំពោះការងារចុះឈ្មោះ គេឱ្យផែនការតែ៨ម៉ឺន តែបានរហូតដល់ ១៦ម៉ឺន ហើយថែមរហូតដល់ ២០២៦ ការិយាល័យ ហើយខេត្តកំពង់ចាមត្រូវធ្វើហិបឆ្នោតថែមជាង ៥០ទៀត ។

**លោក ឱក សេរី សោភក្តិ** បានមានប្រសាសន៍ថា ដោយសារមានវត្តមានក្រុមប្រឹក្សាឃុំសង្កាត់នៅក្នុងអង្គប្រជុំនេះ បញ្ហាព័ត៌មានការគ្រប់គ្រងប្រជាពលរដ្ឋតាមភូមិឃុំជាការសំខាន់ណាស់ ពេលដែលបញ្ជូនតួរលេខទៅក្រសួងមហាផ្ទៃ ព្រោះគ្រាន់តែពិនិត្យ និងចុះឈ្មោះបោះឆ្នោតលើកនេះខុសតួរលេខច្រើនណាស់ ។ គជប រៀបចំប្រដាប់ប្រដារសំរាប់ពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត តែ ៦០ម៉ឺននាក់ ប៉ុន្តែលទ្ធផលជាក់ស្តែងមានដល់ជិត ១លាននាក់ដែលត្រូវចុះឈ្មោះ ។ ដូច្នេះតួរលេខដែលឱ្យពីក្រុមប្រឹក្សាឃុំសង្កាត់ទៅ គជប គឺខុសច្រើនណាស់ តោងតែមានការប្រយ័ត្នឱ្យខ្លាំង ហើយយើងកំពុងតែកែប្រែនៅក្នុងរឿងនេះ ។

**លោក ឡុង ខឿន** ជំទប់ទី១ ឃុំមៀន និងជាប្រធានក្រុមប្រឹក្សា គណបក្សសមរង្ស៊ី ស្រុកអូរាំងឪ ខេត្តកំពង់ចាម បានគាំទ្រទាំងស្រុកលើពាក្យដែលលោកសោភក្តិ ថាបង្កើតវប្បធម៌នៃការពិភាក្សា យើងចេះឈ្លោះគ្នាដើម្បីកសាង ឈប់ឈ្លោះគ្នាដើម្បីបំផ្លាញ។ ទាក់ទងនិងទំនាស់ ទី១អាចកើតចេញពីនយោបាយ ដែលបុគ្គលនៅខាងក្រោមយកនយោបាយ យកគណបក្សធ្វើកម្មសិទ្ធិពេក គឺដូចជាកើ្តពីដូនតាចែកឱ្យមកអញ្ចឹង ។ ទី២ តួនាទី មានបុគ្គលខ្លះមិនស្គាល់ពីតួនាទី រំលោភតួនាទី ។ ទី៣ ចេញពី គជប តែម្តង ។

លោកបានសំណូមពរតាមរយៈលោកលេខាធិការដ្ឋានទៅ គជប បើអាចទៅកើត ស្នើសុំឱ្យមានការបណ្តុះបណ្តាលមន្ត្រីរៀបចំការបោះឆ្នោតនៅខាងក្រោមឱ្យចេះមេរៀនតែមួយឱ្យបានច្បាស់ដូចគ្នា ឱ្យចេះស្គាល់តួនាទីដូចគ្នា ហើយឱ្យមានសមត្ថភាពក្នុងការបំពេញការងារ ។ ជាក់ស្តែងលោកបានលើក ឧទាហរណ៍នៅឆ្នាំ ២០០៣ នៅស្រុកអូរាំងឪ លេខាធិការនៅក្នុងការិយាល័យបោះឆ្នោតបំពេញតួនាទីខ្លួនឯងមិនគ្រប់ជ្រុងជ្រោយទេ បែរជាឱ្យប្រជាពលរដ្ឋទៅផ្ទៀងផ្ទាត់លេខនៅប័ណ្ណខាងក្រៅ តែនេះជាតួនាទីរបស់លេខាធិការ ។ ការដែលផ្ទៀងនៅខាងក្រៅនាំឱ្យបង្កើតភាពរញ៉េរញ៉ៃ បញ្ច្រៀតចុះឡើង១យូរទៅប្រជាពលរដ្ឋធុញ គាត់ទៅផ្ទះបាត់ ។ បញ្ហានេះបង្កើតភាពសង្ស័យមួយទៀត ព្រោះ គជប គេមិនទាន់ឱ្យពិន្ទុថាសុក្រឹត្យ ១០០% គជប ចេញពីគណបក្សនយោបាយ យើងជឿថាមិនងាយរកមនុស្សដែលមានអព្យាក្រឹត្យបានទេ ។ ដល់មកអ្នកនៅខាងក្រោម គឺលេខាធិការធ្វើបែបនេះនាំឱ្យគេសង្ស័យថាទុកល្បិចបន្តិច ធ្វើឱ្យប្រជារាស្ត្រធុញទ្រាន់ នាំមានការបញ្ចេញទស្សនៈខុសប្លែកគ្នា ចុងក្រោយក្លាយជាទំនាស់ ។

**លោក គង់ ថារ៉េត** ជំទប់ទី១ ឃុំវាលវង់ ស្រុកកំពង់ចាម គណបក្ស សមរង្ស៊ី បានមានប្រសាសន៍ទាក់ទិននិងការចុះឈ្មោះបោះឆ្នោត គណកម្មាការរៀបចំការចុះឈ្មោះខេត្តបានថាបើសិនជាអ្នកចង់ប្តឹងឱ្យមានសាក្សី និងវត្តមាន ។ ក្នុងនាមជាអាជ្ញាធរលោកយល់ច្បាស់ពីការចុះឈ្មោះ ដែលការចុះឈ្មោះនេះកាលណាមេឃុំ ក្រុមប្រឹក្សាឃុំជាប់ឆ្នោតនៅក្នុងឃុំរបស់ខ្លួនដឹកនាំប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ប៉ុន្តែដោយឡែកលោកបានឃើញបងប្អូនកងទ័ពឆ្លងកាត់ទន្លេ មានអ្នកជូនមកម្តង ៣០នាក់ ហើយ១៥ ការិយា

ល័យចុះគ្រប់ថ្ងៃ ការដែលមកនេះគឺមានបណ្តឹញមក ។ ក្នុងនាមលោកជាអាជ្ញាធរក៏មានការទទួលខុសត្រូវដែរ ពេលចូលមកលោកសំភាស គាត់បានប្រមូលឯកសារទាំងអស់ដាក់កន្លែងគាត់ មិនឱ្យលោកមើលនិងសួរ ។ លោកចង់ដឹងក៏បានសួរថា តើអ្នកនៅឃុំណាសព្វថ្ងៃ គាត់ឆ្លើយមកវិញថានៅឃុំតាប៉ាវ ស្រុកត្បូងឃ្មុំ ហេតុអ្វីបានជាលោកមកចុះនៅទីនេះ គាត់ឆ្លើយថាគេឱ្យគាត់មកចុះនៅទីនេះ ហើយចុះនៅឃុំណា គាត់ថាមិនស្គាល់ផង ។ ត្រង់ចំណុចនេះលោកសូមបញ្ជាក់ ១០១៩ បញ្ជាក់ប្រជាពលរដ្ឋដែលមកនៅមូលដ្ឋាន ហើយមិនទាន់មានឯកសារគ្រប់គ្រាន់ នេះលោកទទួលស្គាល់ ។

ចំណុចមួយទៀតបើប្តឹងឱ្យមានភស្តុតាង លោកក៏បានទៅថតរូបយកភស្តុតាង ដើម្បីប្តឹងទៅ គជប លោកមេឃុំគាត់ទះផ្លូងថាមិនមានសិទ្ធិអនុញ្ញាតឱ្យថត ហើយខាងនិកហ្វិចក៏បានប្រាប់ថាមិនមានច្បាប់ណាឱ្យថតក្នុងការិយាល័យ និងទីធ្លាការិយាល័យ ។ លោកក៏ថតឯកសារយកទាំងឡាន និងយកកងកំលាំងនៅខាងក្រៅបរិវេណ គាត់ក៏មិនឱ្យថតទៀត ។

បញ្ហាមួយទៀតមានកងរាជអាវុធហត្ថមួយចំនួន មកដល់គាត់សួរលោកថាឯកសារនេះយកជាផ្លូវការដែរទេ លោកបានមើលគឺចុះថ្ងៃ០២ ខែតុលា ទើបតែថ្មី១ គេថាមេគេឱ្យមកចុះទៀតគាត់ចុះនៅត្បូងឃ្មុំរួចហើយ លោកមេឃុំបានឆ្លើយថាគាត់ចុះប៉ុន្មានក៏បានដែរ តែមានសិទ្ធិបោះឆ្នោតតែមួយទេ ។ នេះសូមលោក គជប បំភ្លឺតើករណីនេះស្របច្បាប់ដែរឬទេ ។

ទាក់ទងនិងជនបរទេសមកចុះឈ្មោះបោះឆ្នោត លោកឆ្ងល់ត្រង់ចំណុចមួយ គឺលោកយល់ឃើញថា បើសិនជាលោកខាងនោះថាយកសៀវភៅគ្រួសារមកមានកែ ហើយយកមកចុះ បើគាត់នាំមកគាត់មានសិទ្ធិចុះឱ្យ តែបើលោកផ្ទាល់ឱ្យបងប្អូនមកចុះ បើគាត់ឃើញសៀវភៅកែ គាត់ថាមិនមានសិទ្ធិចុះទេ ព្រោះសៀវភៅកែ ។ បើសិនជាជនបរទេសជាការល្អត្រូវតែមានចេញលិខិតឡាយព្រះហស្ថពីព្រះមហាក្សត្រមកបើយើងចង់ចុះឈ្មោះ ព្រោះអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ គឺសមត្ថកិច្ចប៉ូលីសធ្វើទាំងអស់ មិនតែប៉ុណ្ណោះអាជ្ញាធរចុះបញ្ជីជាតិកំណើតឱ្យទៀត បើថាយកវាមកចុះកាន់តែធ្ងន់ទៀត មានដូចគ្នាទេ តែជាការល្អមានលិខិតចូលសញ្ជាតិ ។

ពាក់ព័ន្ធនិងបញ្ជីឈ្មោះ គជប ថាបើសិនជាអ្នកផ្លាស់ទីលំនៅដឹងច្បាស់សូមឱ្យគូសថាផ្លាស់ចេញ ប៉ុន្តែអាជ្ញាធរដែលជាចាស់ទុំយូរឆ្នាំមកហើយ គ្នាគាត់នៅកំពង់ចាមផ្លាស់ចេញទៅនៅខេត្តកណ្តាល គាត់ហែកទុកឱ្យថាថ្ងៃណាគេមកឃើញបោះ បើមិនឃើញមិនបាច់បោះក៏បានទុកចោលទៅ នេះហើយនាំឱ្យកើនឈ្មោះកាន់តែច្រើន ។ គ្រាន់តែឈ្មោះនៅឃុំវាលវង់នៅសល់ជិត៤ពាន់នាក់ លោកសួរទៅមេភូមិគ្រប់គ្នា គាត់ថាមានឈ្មោះមួយគាត់ធ្វើនៅទីនេះ២៦ឆ្នាំមិនស្គាល់ឈ្មោះនេះសោះ រកមិនឃើញ ។

ទាក់ទងនៅភូមិមួយដែល មានឈ្មោះ គន ច្រើន ហើយឈ្មោះខ្លះមាន២-៣នៅទន្ទឹមគ្នា កាលឆ្នាំ ២០០៣ លោកផ្ទាល់បានលុបឈ្មោះទុកនៅទូលថ្មមួយ ស្រាប់ដល់បោះឆ្នោត ហើយពិនិត្យឥឡូវមានប័ណ្ណព័ត៌មានមកវិញដដែល មិនដឹងចេញពីប្រភពណា លុបមួយហើយចេញមកមួយទៀត ។ ការចុះឈ្មោះនេះដូចជាហិបដែល គជប ឱ្យស្មៀនជាអ្នកទុកហ្នឹង លោកថាការទុកនេះមិនទាន់ជាឯករាជ្យទេ ព្រោះស្មៀនតែធ្វើការរួចទៅបាត់ ជំនួយការស្មៀនបើរួចដឹកទៅ ពេលបូកបញ្ជីបញ្ចប់ប្រចាំថ្ងៃគ្រប់ហើយ តែដល់ប្រកាសលទ្ធផលចុងបញ្ចប់ចេញមកជាផ្លូវការកើនលើស មិនដឹងលើសពីកន្លែងណាមក ។ ចុងក្រោយលោកសូមឱ្យ គជប ពិនិត្យពាក់ព័ន្ធលើបញ្ហាចុះឈ្មោះ ។

**លោកស្រី រស់ សុភក្តិ** អនុប្រធានមន្ទីរកិច្ចការនារីខេត្តកំពង់ចាម ដោយបានស្តាប់អង្គប្រជុំឃើញថាមានភាពតានតឹង និងភាពធូរស្រាខ្លះ ក្នុងការដែលធ្វើឱ្យដំណើរការនៃការបោះឆ្នោត ក៏ដូចជាកិច្ចប្រជុំនេះមានដំណើរការទៅបាន ។ ប្រសិនបើមិនបានវិភាគយើងឃើញថាមានភាពតានតឹង តែបើបានវិភាគវិញឃើញថាមកដល់ពេលនេះ យើងមានធនធានមនុស្សជាច្រើន ហើយក៏មាន

គណបក្សជាច្រើនដែលយើងប្រើពាក្យថា កំពុងតែបើកជំហរលទ្ធិប្រជាធិបតេយ្យ ដែលមានគណបក្សចំរុះចូលធ្វើការជាមួយគ្នា ដើម្បីពិនិត្យ ពិចារណានូវពាក្យដែលយើងចេះតែចោទគ្នាថាពុករលួយ ។

ការដែលមានគណបក្សច្រើននេះហើយដែលធ្វើឱ្យយើងឈានទៅ រកលទ្ធិប្រជាធិបតេយ្យដោយទូលាយនៅក្នុងចំណោមប្រជាជន ដូចជាមតិរបស់ព្រះតេជគុណថា ហេតុអ្វីបានជាជាប់មួយដដែរៗ ។ នេះជាសិទ្ធិរបស់ប្រជាពលរដ្ឋដែលបានធ្វើការជ្រើសរើសដោយខ្លួនឯង មិនមែនយើងនៅក្នុងអង្គប្រជុំនេះជាអ្នកជ្រើសរើសទេ ដូច្នេះដំណាក់កាលនៃការឃោសនា គឺអាស្រ័យដោយគណបក្សនីមួយៗជាអ្នកឃោសនាដើម្បីទាមទារសន្លឹកឆ្នោតដោយខ្លួនឯងថាអ្នកណាត្រូវទទួលបានយ៉ាងដូម្តេច ។

នេះជាបញ្ហាមួយដែលធ្វើឱ្យអង្គប្រជុំធ្វើការពិចារណា ជៀសវាងដែលយើងប្រើពាក្យថា ចេះតែទំនាស់ សូមឱ្យយើងមានសមធមិក្នុងការធ្វើការងារ ប្រសិនបើយើងមានសមធមិទោះបីយើងមានគណបក្សច្រើនក៏ដោយ ក៏មិនមានទំនាស់ដែរ តែបើមិនមានសមធមិទេបញ្ហាតិចតួចអាចបង្កឱ្យមានទំនាស់ ជួនកាលអាចមានបញ្ហាក្នុងពេលបោះឆ្នោត ។ អញ្ចឹងចាប់ពីពេលនេះទៅមុខយើងទាំងអស់សុទ្ធតែតំណាងឱ្យគណបក្សនីមួយៗ ដែលយើងប្រើពាក្យថាអ្នកធំនៅក្នុងចំណោមប្រជាពលរដ្ឋដែលជាអ្នកជ្រើសរើស ។ ដូច្នេះសូមឱ្យយើងជាតួអង្គខ្លួនឯងផ្ទាល់មានសមធមិដោយខ្លួនឯង និងមានសមធមិរវាងគណបក្ស ដែលយើងប្រើពាក្យថាពហុភាគី ។ ឧទាហរណ៍នៅមន្ទីរកិច្ចការនារី សួរថាមានទំនាស់ទេ មានបង្កទំនាស់ទេ គឺមានដែរ តូចចិត្តត្រង់ថាកិច្ចការនារីឈរឈ្មោះមិនដែលបានលេខខ្ពស់ជាងគេ ប៉ុន្តែហេតុអ្វីបានកិច្ចការនារីម៉ោងនេះ ពេលនេះនៅតែប្រើពាក្យសមធមិ ពីព្រោះកិច្ចការនារីប្រជាពលរដ្ឋមិនទាន់យល់ថាត្រូវតែលើកតំលៃស្ត្រីខ្លួនឯង ត្រូវតែបោះឆ្នោតឱ្យស្ត្រីខ្លួនឯងដើម្បីឈរបានខ្ពស់ជាងបុរស ឬបន្ទាប់បុរស ។ ដូច្នេះចេះតែព្យាយាមឱ្យគ្រប់គណបក្ស ដើម្បីយកចិត្តទុកដាក់ស្រឡាញ់នារី ឱ្យនារីបានឈរឈ្មោះជាបេក្ខជន ។ ពីមុនមិនដែលបានឈរ ឥឡូវបានឈរ ឈរហើយជួនកាលនៅទាបបំផុត ជួនកាលបានជាប់ខ្លះក៏មិនតូចចិត្តដែរ ប៉ុន្តែទៅថ្ងៃមុខនឹងគិតថាដៃគូរដ៏ល្អរវាងបុរស និងស្ត្រីគេនឹងមើលឃើញ ។

លោកស្រីបានសំណូមពរសូមឱ្យខាងអង្គការ ខាងគណបក្សទាំងអស់មេត្តាយោគយល់គ្នា ទោះបីនៅក្នុងសកលលោកទាំងមូលក៏មិនទាន់មានសមភាពដែរ សព្វថ្ងៃយើងបញ្ច្រៀបយេនឌ័រចង់បានសមភាព តែទើបតែបានសមធមិទេ ។ យើងចង់បានឱ្យស្ត្រីឈរជាបេក្ខជន តែសង្គមរបស់យើងបិតុធិបតេយ្យ ដូច្នេះពេលដែលបិតុបើកជំហរហ្នឹងហើយ បានជាស្ត្រីចេះតែខំប្រឹង ។

អង្គប្រជុំទាំងអស់នេះគ្រាន់តែជាគំនិតរបស់លោកស្រីផ្ទាល់ អញ្ចឹងចង់ឱ្យបានឈរជាបេក្ខជន ស្ត្រីត្រូវតែប្រឹងរៀន ហើយប្រឹងរៀនហ្នឹងក្រចេះទៀត ដល់អញ្ចឹងគេចេះតែឱ្យនៅក្រោម ។ ការដែលចង់មានឋានៈនៅលើគេមិនមែនចង់ត្រួតគេទេ ប្រើពាក្យថាពង្រឹងអំណាចមិនមែនចង់ត្រួតបុរសទេ គ្រាន់តែចង់ឱ្យមានតួនាទីខ្លះៗនៅក្នុងសង្គម ដើម្បីកែលម្អអ្វីដែលបុរសដើរទៅខុស ហើយឆ្គង ហើយស្ត្រីឋានៈទាបពេកគ្មានសិទ្ធិបញ្ចេញយោបល់ ។

ថ្វីត្បិតតែលោកស្រីជាគណបក្សប្រជាជន ហើយធ្វើការជាមួយគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសមរង្ស៊ី លោកស្រីមិនបានគិតថាស្ត្រីទាំងនោះជាគណបក្សដទៃទេ គឺគិតថាជាមិត្តរួមការងារ អ្នកណាមានសមត្ថភាពត្រូវតែជំរុញគេឱ្យមានឋានៈតួនាទី ។

**លោក សយ សារឿន** ពាក់ព័ន្ធនិងករណីបណ្តឹង លោកគិតថានីតិវិធី និងបទបញ្ជានៃបណ្តឹងគួរតែដាក់ឱ្យដាច់ពីគ្នា ព្រោះថាបទដ្ឋានទាំងពីរនេះមិនដូចគ្នាទេ វាទៅតាមធនធាននៃបរិបទរបស់មនុស្ស ។ លោកបានមានសំណូមពរឱ្យ គជប រកវិធីយ៉ាងណាធ្វើការកែទម្រង់លើបណ្តឹង ឱ្យខ្លី សាមញ្ញងាយបំពេញ ព្រោះបណ្តឹងនេះពាក់ព័ន្ធនិងនីតិវិធី និងកត្តាជាច្រើន ដែលធ្វើឱ្យប្រជាពលរដ្ឋសាមញ្ញ

ធម្មតាមិនពិបាក បើសិនប្រជាពលរដ្ឋចង់ប្តឹង គឺមានការពិបាកណាស់ទម្រង់នេះ ។ សំរាប់គណបក្សនយោបាយមិនសូវមានបញ្ហាទេ ព្រោះគាត់បានសិក្សា ។

លោកបានដាក់អនុសាសន៍ទៅខាងលេខាធិការដ្ឋាន ដើម្បីឱ្យរដ្ឋាភិបាលដាក់ចូលទៅក្នុងច្បាប់ដើម្បីធ្វើវិសោធនកម្ម

**ទី១** ពាក់ព័ន្ធនិងអ្នកសង្កេតការណ៍ លោកចង់ឱ្យមានអ្នកសង្កេតការណ៍រយៈពេលវែងសំរាប់ធ្វើការសង្កេតការណ៍ទៅលើការបោះឆ្នោតទាំងបីដំណាក់កាល ទី១ មុនពេលបោះឆ្នោត ទី២ ពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទី៣ ក្រោយការបោះឆ្នោត ។

**ទី២** ពាក់ព័ន្ធនិងប្រព័ន្ធបោះឆ្នោត ដែលសព្វថ្ងៃនេះយើងបោះតាមប្រព័ន្ធសមាមាត្រ មិនអាចទៅជាឯកត្តនាមទេ អញ្ចឹងសូមឱ្យប្រព័ន្ធសមាមាត្របូកជាមួយនិងឯករាជ្យ ។ បានន័យថាមនុស្សដែលមានសមត្ថភាពខ្ពស់ មានបទពិសោធន៍ មានកេរ្តិ៍ឈ្មោះល្អ ឱ្យគាត់អាចឈរឈ្មោះបានផង កុំឱ្យមានតែគណបក្សនយោបាយទៅឈរឈ្មោះ ។

ជាចុងក្រោយពាក់ព័ន្ធនិងបញ្ជីព័ត៌មានអ្នកបោះឆ្នោត ដោយអង្គប្រជុំបានលើកឡើងថាមានមេភូមិបានលុបឈ្មោះ កែឈ្មោះនៅពេលចែកបណ្ណព័ត៌មាន ដោយលោកបានមើលឃើញនៅក្នុងសៀវភៅជំនួយស្មារតីរបស់ គជប ថាអ្នកដែលមានសិទ្ធិលុបឈ្មោះ ឬកែតំរូវឈ្មោះរបស់ប្រជាពលរដ្ឋមានតែស្មៀនឃុំទេ ។ ដូច្នេះបើសិនជាមេភូមិគាត់លុបបានន័យថាប្រជាពលរដ្ឋគាត់ច្រឡំហើយ គាត់ថាខ្ញុំលទៅកាន់ការិយាល័យឱ្យស្មៀនឃុំលុបណាស់ ព្រោះឈ្មោះគាត់មេភូមិកែរួចហើយ អញ្ចឹងដល់ពេលបោះឆ្នោត គាត់ទៅកាន់ការិយាល័យបោះឆ្នោតឈ្មោះគាត់ត្រូវបានខុសបាត់ រឿងនេះគាត់ខាតគឺបោះបង់ចោលការបោះឆ្នោតទាំងស្រុង ដោយសារការច្រឡំ ។

**លោក មាង ម៉េងហ៊ួន** បានឆ្លើយតបទៅនិងសំណួររបស់អង្គប្រជុំ

**ទី១** បណ្តឹង ដូចអង្គប្រជុំបានដឹងហើយ ព្រមទាំងលោក សយ សារឿនក៏បានប្រាប់ដែរថា ឱ្យកែទម្រង់ ប៉ុន្តែប្រជាជនអាចសរសេរលើក្រដាសសបាន ថាគាត់ប្តឹងពីអី ពីបុគ្គលណា មិនបាច់សុំទម្រង់ពីមេឃុំ និងស្មៀនទេ ។ ចំពោះការកែទម្រង់ លោកក៏គិតថាមានការពិបាកដែរចំពោះប្រជាពលរដ្ឋ ហើយក៏មានសំណូមពរទៅ គជប ចំពោះបញ្ហាទម្រង់ទាំងឡាយ ឥឡូវឃើញមានកាត់បន្ថយអស់ច្រើនហើយ ។

**ទី២** ទាក់ទងនិងមន្ត្រីបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់ ក្រោយពីជាប់ហើយមានការបណ្តុះបណ្តាល ប៉ុន្តែការបណ្តុះបណ្តាលនេះមានរយៈពេលខ្លី ឧទាហរណ៍ នៅថ្នាក់ គខប ថ្ងៃ២០ត្រូវទៅរៀន ហើយយកគ្រូ១៦នាក់ប្រចាំស្រុក ក្រោយពីបានជាប់ ទៅរៀន២ថ្ងៃ ហើយយកគ្រូមកបង្រៀននៅ CEC ពេលដែលយើងជ្រើសរើសមន្ត្រីបោះឆ្នោតឃុំ ហើយឃុំរៀនពីលោកគ្រូនេះទៅ យកទៅបង្រៀនការិយាល័យបន្តទៀត ។ ចំណែកឯការយល់ដឹង ហើយគ្រូឧទ្ទេសនាមបន្តក៏មានផលលំបាក យើងកដឹងហើយថាការទទួលចំណេះដឹងពីមួយទៅមួយគឺមានផលលំបាកណាស់ ព្រោះកំរិតវប្បធម៌មន្ត្រីបោះឆ្នោតថ្នាក់ការិយាល័យមិនស្មើគ្នាទេ ។ ចំពោះស្មៀនឃុំមួយចំនួនគាត់នៅមានកំរិតវប្បធម៌ទាប នាំឱ្យគាត់មិនសូវចាប់បានពីការងារ ប៉ុន្តែក៏មានស្មៀនថ្មីគេធ្វើការងារបានល្អដែរ ។

**ទី៣** ពាក់ព័ន្ធនិងរឿងយោធា លោកបានមានប្រសាសន៍ថាកាលលោកបានប្រជុំបញ្ហាការឯកភាពនៅខេត្ត ខាងយោធា និងកងអាវុធហត្ថទាំងបីប្រភេទ បានឆ្លើយនៅក្នុងអង្គប្រជុំរួចហើយ ព្រោះលោកក្តាប់បាននៅក្នុងកំណត់ហេតុ គឺកងប្រដាប់អាវុធនៅពេលបោះឆ្នោតគេត្រៀមការងារការពារក្នុងកិច្ចដំណើរការបោះឆ្នោត ។ គាត់មិនទៀង ជួនកាលគេបោះទីតាំងសំរាប់អន្តរាគមន៍ អញ្ចឹងគាត់ត្រូវតែឈរជើងនៅទីប្រជុំជន ។

**លោក ឱក សេរី សោភក្តិ** សូមឱ្យអង្គប្រជុំចាប់អារម្មណ៍លើប្រសាសន៍របស់លោក ថារ៉េត ដែលបានលើកពីរឿងកងទ័ពដែលដឹកយកពីឃុំនេះ ទៅចុះនៅឃុំនោះ ។ លោកសូមឱ្យមានព័ត៌មានឱ្យច្បាស់ពីចំនួន កន្លែងណា ឈ្មោះភូមិឃុំ ដើម្បីខប់សែលនឹងលើក

យកបញ្ហានេះទៅជំរាបជូននៅថ្នាក់ជាតិ ព្រោះនេះជាព័ត៌មានសំខាន់ ហើយនៅខេត្តផ្សេង ទៀតខប់សែលបានឮដូចគ្នា គេក៏បានធ្វើការស៊ើបអង្កេតសុំព័ត៌មានច្បាស់ដូចគ្នាដែរ ។ ចំណុចនេះគឺខុសនីតិវិធីតែម្តង ព្រោះបើសៀវភៅ ក៤ មានអាសយដ្ឋាននៅកន្លែងណា យើងចុះបានតែកន្លែងនោះទេ មិនអាចឆ្លងឃុំបានទេ ។

មានកិច្ចការមួយចំនួនដែលអង្គប្រជុំខប់សែលបានបើកទ្វារ ដើម្បីឱ្យយើងលើកបញ្ហាមួយចំនួន ដែលគ្រាន់តែជាការចាប់ផ្តើមទេ ចាប់ពីពេលនេះតទៅត្រូវតែសហប្រតិបត្តិការជាមួយខាង PEC និង CEC នៅខេត្តកំពង់ចាម នៅពេលដែលបានរើសសមាជិក ឬមន្ត្រីដែលចាប់ផ្តើមធ្វើការហ្វឹកហាត់ជាមួយគ្នានោះ ។ ខប់សែលសង្ឃឹមថាដំណាក់ទីមួយ១ជាពិសេសយុទ្ធនាការឃោសនាបោះឆ្នោត ១៥ ថ្ងៃមុនថ្ងៃ ០១ ខែមេសា នឹងបានប្រព្រឹត្តទៅដោយសុវត្ថិភាព មិនមានយប់ឡើងឆ្កែព្រូសទេ ។ កិច្ចការទាំងអស់នេះយើងកំពុងធ្វើការជាមួយគ្រប់ក្រសួង គ្រប់មន្ទីរ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ។

**អ្នកស្រី Margie Cook** សូមថ្លែងអំណរគុណ និងសំដែងនូវការចាប់អារម្មណ៍ជាខ្លាំងចំពោះចំពោះកិច្ចពិភាក្សានៅក្នុងអង្គប្រជុំនេះ ដែលបានលើកឡើងនូវបញ្ហាសំខាន់ និងបញ្ហាដែលប្រឈមមុខជាច្រើន ហើយជាពិសេសការពិភាក្សានេះអាចផ្តល់ជាឱកាសមួយបើកទូលាយសំរាប់ការស្វែងរកដំណោះស្រាយលើបញ្ហានានាដែលកើតមាន ។ ជាទស្សនៈរបស់អ្នកស្រីផ្ទាល់ ជាពិសេសក្នុងនាមតំណាង UNDP គឺមានចំណាប់អារម្មណ៍លើបញ្ហាដែលបានលើកឡើងទាំងអស់នេះ អ្នកស្រីព្រមទាំងបានសន្យាថានឹងតាមដានជាបន្តទៀត ដែលបញ្ហានោះទាក់ទងនិងយន្តការដ៏មានប្រសិទ្ធភាពមួយជុំវិញការចែកជូនប័ណ្ណព័ត៌មាន តើយើងធ្វើយ៉ាងម៉េចដើម្បីឱ្យមានប្រសិទ្ធិភាពល្អ ។ នៅក្នុងន័យនេះ UNDP មានគោលបំណង និងមានជារបៀបវារៈនៅក្នុងកម្មវិធីរបស់ខ្លួនរួចជាស្រេច ដើម្បីថាតើយើងគួរធ្វើយ៉ាងណាដើម្បីចែកចាយប័ណ្ណព័ត៌មានឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋគ្រប់ៗគ្នា នៅពេលខាងមុខនេះ ។

ទាក់ទងនិងរឿងការអប់រំផ្សព្វផ្សាយ ការបណ្តុះបណ្តាល ជាពិសេសការជូនព័ត៌មានតាមរយៈការផ្សព្វផ្សាយ ។ ចំណុចមួយទៀតទាក់ទងថា តើយើងធ្វើយ៉ាងម៉េចឱ្យមានលក្ខណៈឯកភាពគ្នាជុំវិញរឿងកាតបោះឆ្នោត និងអត្តសញ្ញាណប័ណ្ណ ។

ចំណុចចុងក្រោយដូចអង្គប្រជុំបានដឹង និងលោកស្រី សុភក្តិបានលើកឡើងហើយថា ស្ត្រីមានជាងពាក់កណ្តាលនៃប្រជាពលរដ្ឋលើពិភពលោក ហើយអ្នកស្រីផ្ទាល់មានចំណាប់អារម្មណ៍ជាពិសេសចំពោះតួនាទីរបស់ស្ត្រីក្នុងការចូលរួមនៅក្នុងនយោបាយ ។ អ្នកស្រីបានចាប់អារម្មណ៍និងសំដីរបស់លោកស្រី សុភក្តិនៅចំណុចចុងក្រោយគឺមានសារៈសំខាន់ណាស់ ។ អ្នកស្រីពិតជាមានការរន្ធត់ណាស់ដែលបានដឹងថាឈ្មោះរបស់ស្ត្រីឋិតនៅលេខរៀងខាងក្រោមនៃបញ្ជីបេក្ខភាពឈរឈ្មោះបោះឆ្នោត ។ ចំណុចនេះមួយធ្វើឱ្យមានការលំបាក ដែលថាយើងធ្វើយ៉ាងម៉េចដើម្បីធានាឱ្យមានសមធម៌យេនឌ័រ ។ បញ្ហាទាំងអស់នេះហើយគឺជាចំណុចមួយដែលត្រូវការពិភាក្សាបន្ថែម និងដោយមានការចូលរួមយ៉ាងច្រើនពីសំណាក់លោកស្រី អស់លោកទាំងអស់ ។

ជាចុងក្រោយអ្នកស្រីបានថ្លែងអំណរគុណចំពោះការចូលរួម និងការលើកឡើងនូវមតិរបស់អង្គប្រជុំទាំងមូល ដែលមានភាពសស្រាក់សស្រាំ និងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយសង្ឃឹមថាអ្នកស្រីនឹងមានឱកាសចូលរួមខប់សែលប្រ៊មនៅខេត្តកំពង់ចាមម្តងទៀត ។

**លោក ឡារី ស្រ្តេន្ទ** បានមានប្រសាសន៍ថ្លែងអំណរគុណជាថ្មីម្តងទៀតដល់អង្គប្រជុំទាំងមូល ហើយលោកបានលើកឡើងនូវចំណុច ៣

**ទី១** លោកផ្ទាល់មានកិត្តយស និងសេចក្តីសប្បាយរីករាយណាស់ដែលបានអង្គុយនៅកន្លែងមួយ ដែលបង្ហាញពីការកសាងលទ្ធិប្រជាធិបតេយ្យដ៏ចាស់ចិត្តចាស់គំនិត តាមរយៈការពិភាក្សានេះ ។

**ទី២** ជាចំណុចសំខាន់សំរាប់វិទ្យាស្ថាន CDRI និងខប់សែល ថាតើយន្តការអ្វីដែលធ្វើឱ្យមានភាពសុក្រឹត្យនៅក្នុងការចែកប័ណ្ណព័ត៌មានដល់ប្រជាពលរដ្ឋសំរាប់ពិនិត្យមើល ។ នេះគឺជាចំណុចសំខាន់ ព្រោះជាមូលដ្ឋានមួយ ដើម្បីជំរុញឱ្យមានតម្លាភាពនៅក្នុងការធានាឱ្យបាននូវការបោះឆ្នោតមួយប្រកបទៅដោយត្រឹមត្រូវ និងយុត្តិធម៌ ជាពិសេសធានាឱ្យមានការឯកភាពគ្នា និងការទទួលខុសត្រូវរវាងគណបក្សនយោបាយ និងភាគីពាក់ព័ន្ធនានាជុំវិញការងារបោះឆ្នោត ។

**ទី៣** សូមថ្លែងអំណរគុណដល់លោក ឱក សេរី សោភ័ក្តិ ។ លោកផ្ទាល់មកពីប្រទេសអូស្ត្រាលី ហើយបានធ្វើការនៅប្រទេសកម្ពុជាបានជាង៣ ឆ្នាំ ជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI លោកមកពីប្រទេសមួយដែលមានលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំ និងយូរអង្វែង ប៉ុន្តែមុននិងឈានបាននូវការកសាងធម្មនុញ្ញប្រកបដោយលទ្ធិប្រជាធិបតេយ្យរឹងមាំនេះ គឺមានមេរៀនមួយដល្អដែលលោកនឹងចែករំលែក គឺយើងត្រូវការពេលវេលាយូរអង្វែងណាស់ដើម្បីធ្វើឱ្យបានធម្មនុញ្ញមួយប្រកបដោយលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ស្ថេរភាព ហើយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។ យើងបានព្យាយាមធ្វើមួយជំហានម្តងៗ ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ដូចជាអាជ្ញាធរ អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ ដើម្បីធានាឱ្យបានថាសមិទ្ធិផលទាំងអស់នេះគឺអាចទទួលបានទាំងអស់គ្នា ហើយគោរព និងអនុវត្តទាំងអស់គ្នា ។ នេះជាគោលបំណងសំខាន់របស់ខប់សែលដែលចង់បាន ដូចអ្វីដែលយើងទាំងអស់គ្នាចង់បានដែរ ដូចនៅក្នុងប្រទេសរបស់លោកដែរ ។

ជាចុងក្រោយលោកសូមសំដែងនូវការកោតសរសើរ និងឆន្ទះនៃការចូលរួមយ៉ាងមុតមាំ និងសកម្មរបស់អង្គប្រជុំនេះ ។ លោកក៏សូមថ្លែងអំណរគុណដល់លោក សោភ័ក្តិ ដែលបានសំរបសំរួលយ៉ាងប៉ិនប្រសព្វសំរាប់កិច្ចប្រជុំខប់សែលប្រ៊ុម និងអរគុណដល់ក្រុមខប់សែលដែលបានរៀបចំកិច្ចប្រជុំនេះប្រកបទៅដោយផ្លែផ្កា ជាពិសេសសូមថ្លែងអំណរគុណដល់ UNDP ដែលបានគាំទ្រលើផ្នែកថវិការទាំងស្រុងលើកម្មវិធីខប់សែលរបស់វិទ្យាស្ថាន CDRI ។

**លោក ឱក សេរី សោភ័ក្តិ** បានជំរាបជូនអង្គប្រជុំពីព័ត៌មាន និងចំណាប់អារម្មណ៍ ដោយក្រុមការងាររបស់ខប់សែលបានឆ្លងកាត់ខេត្តច្រើនណាស់ ហើយក្នុងខេត្តនីមួយៗថ្វីត្បិតតែប្រធានបទ និងបញ្ហាដែលយើងបានជជែកជាមួយមានស្រដៀងគ្នា ប៉ុន្តែរបៀបដែលលើកឡើង សំដី ការទំនាក់ទំនងរវាងតួអង្គដែលលើកឡើងមានលំនាំទៅតាមខេត្តរៀងៗខ្លួន ។ ចំណុចមួយដែលខេត្តណាក៏មានដែរតាមខេត្តដែលខប់សែលបានឆ្លងកាត់ ហើយដែលគួរឱ្យសង្ឃឹម គឺភាពថ្លៃថ្នូ និងភាពចាស់ចិត្តចាស់គំនិត ចាស់ទុំនៃតួអង្គនៅក្នុងយន្តការនៃការបោះឆ្នោតទាំងអស់ ទោះបីជាប្រធានបទក្តៅយ៉ាងណាក៏ដោយ ដូចជានៅក្រុងប៉ៃលិន មានចង្អុលមុខគ្នាទៅវិញទៅមករវាងប៉ូលិស សង្គមស៊ីវិល និងគណបក្សនយោបាយ ប៉ុន្តែមិនដែលឆ្លងទៅរកការខ្វះភាពថ្លៃថ្នូ និងការគោរពគ្នាទៅវិញទៅមកទេ ធ្វើអោយយើងជឿជាក់ថាប្រទេសកម្ពុជា សង្គមកម្ពុជា ប្រជាពលរដ្ឋកម្ពុជា តួអង្គនយោបាយទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន កំពុងតែឈានទៅរកគំរិតមួយដែលអាចនិយាយពិភាក្សាគ្នាបានដោយសន្តិភាព នៅក្នុងការរួមកំលាំងគ្នា ទោះបីជាការយល់ឃើញមិនដូចគ្នា ក៏ដោយ ប៉ុន្តែការគោរពគ្នាទៅវិញទៅមកគឺមានគ្រប់កន្លែង ។ នេះជាមោទនៈភាពរបស់យន្តការខប់សែល ហើយការធ្វើបែបនេះជាការសំខាន់ណាស់ ព្រោះលោកផ្ទាល់បានមកប្រជុំនៅបន្ទប់នេះជាលើកទី៤ ហើយម្តងណាក៏បន្ទប់នេះដូរដែរ ដូរតាំងពីគ្មានម៉ាស៊ីនត្រជាក់ មកមានដូរតាំងពីកខ្វក់មកស្អាត ដូរតាំងពីស្អាតល្មមកភ្លឺង ។ ហើយកម្ពុជាដូចគ្នាដែរ កាលដែលលោកចូលមកពីឆ្នាំ ១៩៩២ មើលមិនយល់ទេ តែឥឡូវសភាពប្រែអស់ហើយ ។

ការដែលបានមកប៉ុណ្ណឹងលំបាកណាស់ ហើយត្រូវរួមគ្នាដើម្បីធ្វើទៅបាន យន្តការបោះឆ្នោត ប្រជាពលរដ្ឋមានសេចក្តីក្លាហានដើម្បីបញ្ចេញមតិរបស់លោក ។ ការជជែកគ្នាមិនអាចជៀសពីនេះបានដាច់ខាត បើជៀសពីនេះ នឹងត្រឡប់ទៅរកសង្គ្រាមវិញជាមិន

ខាន ហើយអ្វីដែលយើងឃើញនៅជុំវិញខ្លួនយើង ខំកសាងមកយូរណាស់ ប៉ុន្តែបើបំផ្លាញទៅវិញលឿនណាស់ ។ តើយើងទុកដំណែលទៅកូនចៅជំនាន់ក្រោយជាកេរ្តិ៍មរតកដែលយើងធ្លាប់ជួបប្រទេះខ្មោងងឹត ខ្លោចផ្សារ ឬជាមរតកមួយដែលពោរពេញទៅដោយសេចក្តីស្រឡាញ់ ពោរពេញទៅដោយវប្បធម៌នៃការជជែកពិភាក្សាគ្នា និងការគោរពគ្នាទៅវិញទៅមកក្នុងសភាពថ្លៃថ្នូ ។ នេះហើយជាការដែលខប់សែលចង់បាននៅពេលដែលលោកបានគូសវាសយន្តការនេះ លោកស្រមៃឃើញបែបនេះ ឥឡូវការស្រមៃនោះបានក្លាយមកជាការពិត ហើយ UNDP បើសិនជាយើងធ្វើមិនបានក៏មិនជួយយើងដែរ ទាល់តែយើងខ្មែរខ្លួនឯងយើងធ្វើអ្វីដែលយើងរួមគ្នាកសាងជាមួយគ្នា បានអ្នកក្រៅគេមកជួយយើងបាន ។ ខប់សែលគឺជាឧទាហរណ៍មួយជាក់ស្តែងមិនអាចប្រកែកបាន ។

ជាចុងក្រោយខប់សែលមានកិត្តយសណាស់ដែលបានមកជួបនៅពេលនេះ ខប់សែលនិងជួបអង្គប្រជុំម្តងទៀត ដើម្បីនិងបំរើនូវការបោះឆ្នោតជាតិឆ្នាំ ២០០៨ ។ លោកសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងទេវតាទាំង ១ម៉ឺនលោករូបធាតុដែលថែរក្សាស្វេតឆ័ត្រ និងថែរក្សាទឹកដីកម្ពុជា ទឹកដីខេត្តកំពង់ចាម សូមជួយថែរក្សាលោកស្រី អស់លោក និងក្រុមគ្រួសារឱ្យបានប្រកបតែនឹងពុទ្ធពរទាំង ៥ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។